**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការយុទ្ធសាស្ត្រថវិកា
# សម្រាប់ឆ្នាំ ២០២១-២០២៣

# លេខកូដ ២៩

# របស់

# ក្រសួងធនធានទឹក និងឧតុនិយម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ ឆ្នាំ ២០២១-២០២៣**

**របស់ក្រសួងធនធានទឹក និងឧតុនិយម**

## I-សេចក្តីផ្តើម

ទឹកជាធនធានមួយយ៉ាងសំខាន់ ដែលមិនអាចខ្វះបានសម្រាប់មនុស្ស សត្វ រុក្ខជាតិគ្រប់ប្រភេទ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ តាមលក្ខណៈភូមិសាស្ត្រ ព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយសម្បូរទៅដោយធនធានទឹក ទន្លេ ស្ទឹង បឹងបួរ ល្អាងទឹកធម្មជាតិក្រោមដី និងសមុទ្រជាដើម គឺជាប្រភពធនធានទឹកដ៏សំខាន់សម្រាប់បម្រើឲ្យដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចជា កសិកម្ម សិប្បកម្ម ឧស្សាហកម្ម ថាមពលអគ្គិសនី នាវាចរណ៍ ការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅប្រចាំថ្ងៃ ។

វិសាលភាពទឹកនៃទន្លេមេគង្គកម្ពុជា ដោយរួមបញ្ចូលទាំងបឹងទន្លេសាប ទន្លេសាប ព្រមទាំងដៃទន្លេនានាទៀត មានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា និងទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ហើយផ្តល់នូវធនធានជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តែយើងកែច្នៃនូវធនធាននេះមកប្រើប្រាស់ ពុំទាន់បានអស់លទ្ធភាពនៅឡើយទេ ។

ប្រជាជនកម្ពុជាភាគច្រើនជួបប្រទះនឹងភាពខ្វះខាតទឹកនៅរដូវប្រាំង ព្រមទាំងមានកូនរដូវប្រាំង ដែលតែងតែកើតមានឡើងនៅក្នុងរដូវវស្សាផលដែរ។ នៅរដូវវស្សាមានទឹកសម្បូរហូរហៀរហើយនៅកន្លែងខ្លះបានជួបប្រទះនូវបរិមាណទឹកលើសពីសេចក្តីត្រូវការ ហើយនៅកន្លែងខ្លះទៀត ប្រឈមទៅនឹងកង្វះខាតទឹក ដោយពុំមានហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពគ្រប់គ្រាន់ និងមានសភាពចាស់ទ្រុឌទ្រោម ដែលមានការលំបាកដល់ការរក្សាទឹកទុក ការបែងចែកទឹក និងការផ្តល់ទឹក សម្រាប់វិស័យកសិកម្ម និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ។

ប្រភពទឹកក្រោមដី ក៏មានសារៈសំខាន់ផងដែរ នៅក្នុងការផ្គត់ផ្គង់ទឹក ការថែរក្សានូវតុល្យភាពទឹក និងជាប្រភពទឹកសាបដ៏សំខាន់ សម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ការស្រោចស្រពដំណាំកសិកម្ម ឧស្សាហកម្ម ហើយអាចមានលទ្ធភាពផ្តល់ទឹកបានស្ទើរពេញមួយឆ្នាំ ។ បច្ចុប្បន្នការបែងចែក និងការកំណត់បរិមាណទឹកក្រោមដី ពុំទាន់មានទិន្នន័យ និងព័ត៌មានច្បាស់លាស់នៅឡើយទេ ។

ដើម្បីគ្រប់គ្រងធនធានទឹកឲ្យបានល្អប្រសើរ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើនការវិនិយោគលើការស្តារ និងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក ដើម្បីជៀសវាងការប្រើប្រាស់គ្មានសណ្តាប់ធ្នាប់ និងការខូចខាតទៅលើធនធានទាំងនោះ ដែលបង្កភាពអន្តរាយដល់កិច្ចអភិវឌ្ឍយូរអង្វែងរបស់ប្រទេសជាតិ ។

ទឹក គឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចអភិវឌ្ឍលើគ្រប់វិស័យនៃសេដ្ឋកិច្ចជាតិ នាពេលបច្ចុប្បន្ន និងអនាគត ហើយក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចទទួលខុសត្រូវរាល់ទិដ្ឋភាពទាំងអស់នៃធនធានទឹករបស់ជាតិ ដើម្បីធានាឲ្យមាននិរន្តរភាព សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដែលទាក់ទងនឹងវិស័យទឹក ដូចជា ការផ្គត់ផ្គង់ទឹកសម្រាប់វិស័យកសិកម្ម ការផ្គត់ផ្គង់ទឹកនៅទីក្រុង និងជនបទ វារីអគ្គិសនី ការនេសាទ គមនាគមន៍ និងទេសចរណ៍ជាដើម ។

ដោយផ្អែកលើអត្ថប្រយោជន៍នៃទឹក ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម និងភារកិច្ចរបស់ខ្លួននោះ ក្រសួងធនធានទឹក និងឧតុនិយម រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លើវិស័យធនធានទឹក និងឧតុនិយម (២០១៩-២០២៣) ដើម្បីបង្ហាញអំពីគោលបំណង គោលដៅ និងសកម្មភាពនានារបស់ក្រសួង ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក និងឧតុនិយម (២០១៩-២០២៣) ។ ផែនការយុទ្ធសាស្ត្រនេះ ផ្តល់នូវទិន្នន័យ ដើម្បីបញ្ចូល និងមានសង្គតិភាព ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩-២០២៣) កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា (២០១៩-២០២៣) ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជា ក្នុងគោលបំណងសម្រេចឲ្យបានគោលដៅចំបងនៃការកាត់បន្ថយភាពក្រីក្រ ។

**១- បេសកកម្ម ភារកិច្ចចម្បងៗ និងរចនាសម្ព័ន្ធ**

ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍ លើវិស័យធនធានទឹក និងឧតុនិយម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យមានប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព សម្រាប់ពេលបច្ចុប្បន្ន និងអនាគតនោះ ក្រសួងធនធានទឹក និង ឧតុនិយម អាជ្ញាធរទន្លេសាប និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវអនុវត្តបេសកកម្ម មុខងារភារកិច្ច និងរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

**ក. ក្រសួងធនធានទឹក និង ឧតុនិយម**

បេសកកម្ម ភារកិច្ចចម្បងៗ និងរចនាសម្ព័ន្ធ របស់ក្រសួង

**ក.១. មុខងារ និងភារកិច្ច**

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយមបម្រើដល់ការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការថែរក្សាការពារប្រកបដោយនិរន្តរភាពជាលក្ខណៈជាតិ និងអន្តរជាតិស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវនូវសក្តានុពលទឹក រួមទាំងទឹកលើដី ទាំងទឹកក្រោមដី និងទឹកលើអាកាស ក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីបង្កើតឡើងនូវមូលដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រច្បាស់លាស់
- លើកទិសដៅផែនការរយៈពេលខ្លី មធ្យម និងវែង ក្នុងការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងថែរក្សាការពារនូវធនធានទឹក ដើម្បីបម្រើដល់សេដ្ឋកិច្ចជាតិ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទាំងនៅទីក្រុង ទាំងនៅជនបទ
- គ្រប់គ្រង ត្រួតពិនិត្យនូវរាល់ការធ្វើអាជីវកម្មលើធនធានទឹកដោយផ្ទាល់ និងប្រយោលប្រកបដោយសនិទានភាព និងកាត់បន្ថយឲ្យបានជាអតិបរមានូវគ្រោះមហន្តរាយដែលអាចកើតមានឡើង ។
- រៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋាន និងបទបញ្ញាត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក និងឧតុនិយម ព្រមទាំងតាមដានលើការអនុវត្ត
- ប្រមូលចងក្រងឯកសារ និងធ្វើអាជីវកម្ម នូវទិន្នន័យឧតុនិយម និងជលសាស្ត្រ បម្រើដល់វិស័យនានាដែលមានការពាក់ព័ន្ធជាលក្ខណៈជាតិ និងអន្តរជាតិ ដើម្បីផលប្រយោជន៍សង្គមជាតិទាំងមូល
- ផ្តល់ការគាំទ្រ និងការណែនាំបច្ចេកទេសជាចាំបាច់ដល់ឯកជន អង្គការវិជ្ជាជីវៈ សហគមន៍ និងប្រជាពលរដ្ឋទូទៅដែលមានការពាក់ព័ន្ធដើម្បីកែលម្អ និងធ្វើអាជីវកម្មធនធានទឹកឲ្យបានសមស្រប
- ពង្រីក និងបញ្ចូលនូវបច្ចេកវិទ្យាទំនើបៗ ដើម្បីមានវិធានការបណ្តុះបណ្តាល កែលម្អ និងផ្សព្វផ្សាយ
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងការងារសហប្រតិបត្តិការអន្តរជាតិលើវិស័យធនធានទឹក និងឧតុនិយម
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង

## ក.២. រចនាសម្ព័ន្ធ ៖

នៅថ្នាក់កណ្តាល

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គាធិការដ្ឋាន ទទួលបន្ទុក
  - ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងធនធានទឹក និងឧតុនិយម
  - ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចរួចហើយ និងពីមធ្យោបាយកែលម្អការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ
  - ប្រតិបត្តិភារកិច្ច តាមការដែលរដ្ឋមន្ត្រីបានប្រគល់ទំនុកចិត្ត
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុក
  - ពិនិត្យឡើងវិញលើមុខងារ សកម្មភាពកិច្ចសហប្រតិបត្តិការ និងកម្មវិធីរបស់អង្គភាពក្នុងការិយបរិច្ឆេទសមស្របរបស់ថ្នាក់ដឹកនាំក្នុងការអនុវត្តឲ្យបានត្រឹមត្រូវលើការបង្កើតផែនការ ការតម្រង់ទិស ការចាត់ចែង និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលការណ៍ណែនាំ គោលនយោបាយ និងនីតិវិធី នៃការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមគោលដៅរបស់អង្គភាព
  - កំណត់នូវភាពសមស្របគ្រប់គ្រាន់ និងផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព
  - ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន ភាពទាន់ពេលវេលា និងភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុ និងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលបានប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណវាស់វែងចំណាត់ថ្នាក់ និងរាយការណ៍ព័ត៌មានទាំងនោះ
  - ពិនិត្យឡើងវិញលើប្រព័ន្ធដែលបានបង្កើតដើម្បីធានាបានទៅតាមគោលនយោបាយផែនការ នីតិវិធីច្បាប់ទាំងឡាយដែលមានឥទ្ធិពលសំខាន់លើកិច្ចប្រតិបត្តិការ និងរបាយការណ៍។ ក្នុងករណីស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ អនុវត្តពុំបានសមស្របដូចបានរៀបរាប់ខាងលើ ចាំបាច់សំណូមពរឲ្យមានការផ្លាស់ប្តូរ និងកែលម្អ
  - ពិនិត្យឡើងវិញលើការគ្រប់គ្រងថែទាំការពារ និងផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិដែលមានឲ្យបានត្រឹមត្រូវ
  - វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពលើការប្រើប្រាស់ធនធាន និងកំណត់ការកែលំអលើការអនុវត្តន៍កិច្ចប្រតិបត្តិការ និងផ្តល់អនុសាសន៍
  - ពិនិត្យឡើងវិញលើកិច្ចប្រតិបត្តិការកម្មវិធីនិងគម្រោងចំណាយមូលធនលើលទ្ធផលការងារវិជ្ជមាន ឬអវិជ្ជមានតាមគោលបំណងគោលដៅដែលបានដាក់ចេញ និងតាមផែនការដែលបានកំណត់
  - ចូលរួមបង្កើតផែនការ ការអភិវឌ្ឍន៍ ការអនុវត្ត និងកិច្ចប្រតិបត្តិការលើប្រព័ន្ធកុំព្យូទ័រសំខាន់ៗ ដើម្បីឲ្យ ៖

    .តម្រូវការរបស់អ្នកប្រើប្រាស់ត្រូវបានកំណត់ច្បាស់លាស់

    .ការត្រួតពិនិត្យផ្ទៃក្នុងសមស្របត្រូវបានបញ្ចូនទៅក្នុងប្រព័ន្ធកុំព្យូទ័រ

    .ការសាកល្បងនៃប្រព័ន្ធកុំព្យូទ័រ ត្រូវបានប្រព្រឹត្តទៅក្នុងជំហានសមស្រប

    .ការកត់ត្រាពីប្រព័ន្ធកុំព្យូទ័រត្រូវបានធ្វើពេញលេញ និងមានភាពត្រឹមត្រូវ

- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗក្រោយពេលដំឡើងរួច ដើម្បីកំណត់ប្រព័ន្ធទាំងនេះឆ្លើយតបតាមគោលបំណង និងគោលដៅដែលបានគ្រោងទុក ហើយទទួលលទ្ធផលមានសុវត្ថិភាព និងប្រសិទ្ធិភាពខ្ពស់
- ពិនិត្យឡើងវិញលើនីតិវិធី និងការអនុវត្តដើម្បីធានាថាវិធានការបានដាក់ចេញក្នុងគោលបំណងការពារការកេងបន្លំ ។ ប្រសិនបើការកេងបន្លំកើតឡើង ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអាចរកឃើញបានទាន់ពេលវេលា
- ត្រួតពិនិត្យឡើងវិញលើការអនុវត្តតាមគោលការណ៍ណែនាំ និងការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលស្តីពីឥរិយាបថ និងក្រមសីលធម៌ចំពោះមន្ត្រីរាជការ
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអាជ្ញាធរសវនកម្មជាតិដើម្បីធានាទំហំការងារឲ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា
- ធ្វើរបាយការណ៍ទៅប្រធាន ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈរបស់ខ្លួនហើយ ត្រូវធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាន នៃការសវនកម្មនេះទៅអាជ្ញាធរសវនកម្មជាតិស្តីពី ៖
  . សកម្មភាពកែលម្អតាមអនុសាសន៍សំខាន់ៗរបស់សវនកម្មផ្ទៃក្នុង
  . សកម្មភាពសវនកម្មត្រូវបានផ្តោតលើហានិភ័យ និងបង្កើតភាពសន្សំសំចៃប្រសិទ្ធភាព និងផ្តល់លទ្ធភាពក្នុងប្រតិបត្តិការ
  . សវនកម្មផ្ទៃក្នុង ត្រូវធ្វើការសម្របសម្រួលការងារជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីជៀសវាងការធ្វើសវនកម្មស្ទួនគ្នា ។ ក្នុងករណីមានភាពមិនច្បាស់លាស់អាជ្ញាធរសវនកម្មជាតិ អាចធ្វើការត្រួតពិនិត្យ និងធ្វើសវនកម្មឡើងវិញ
  . ផែនការសវនកម្មផ្ទៃក្នុង ត្រូវមានភាពសមស្របច្បាស់លាស់ គ្រប់គ្រាន់
  . ការរារាំងលើព័ត៌មាន និងបញ្ជី
- ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំត្រូវដាក់ជូនថ្នាក់ដឹកនាំស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ពិនិត្យ និងសម្រេច
- វាយតម្លៃផែនការ ឬសកម្មភាពកែលម្អ លើចំណុចរកឃើញរបស់សវនករផ្ទៃក្នុង ។ ប្រសិនបើសកម្មភាពកែលម្អនេះមិនមានលក្ខណៈសមស្របទេនោះត្រូវលើកយកមកពិភាក្សាបន្ត ដើម្បីឲ្យសម្រេចបានតាមសំណូមពរដែលអាចទទួលយកបាន
- ផ្តល់លទ្ធភាពសមស្របគ្រប់គ្រាន់ក្នុងការតាមដានសកម្មភាពកែលម្អលើអនុសាសន៍
- ប្រធានសវនកម្មផ្ទៃក្នុង ត្រូវរាយការណ៍ដោយផ្ទាល់ជូនថ្នាក់ដឹកនាំស្ថាប័ន ក្រសួង ឬក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ
- ធ្វើរបាយការណ៍ និងសេចក្តីសន្និដ្ឋាននៃសវនកម្មធ្វើជូនដល់ផ្នែកនីមួយៗរបស់ស្ថាប័នក្រសួង និងសហគ្រាសសាធារណៈដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍ ។ សវនកម្មផ្ទៃក្នុងត្រូវបញ្ជូនរាល់របាយការណ៍ និងសេចក្តីសន្និដ្ឋានទៅថ្នាក់អង្គភាពរបស់ខ្លួន និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ
- អនុវត្តរាល់ការងារនិងភារកិច្ចផ្សេងៗ ដែលប្រធានស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈប្រគល់ឲ្យ

- **អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល** ទទួលបន្ទុកធ្វើទំនាក់ទំនង សម្របសម្រួល និងគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សម្ភារបរិក្ខារ គណនេយ្យហិរញ្ញវត្ថុ ផែនការស្ថិតិ តាមដាន និងវាយតម្លៃការងារសហប្រតិបត្តិការជាតិ និងអន្តរជាតិ ការងារបណ្តុះបណ្តាលធនធានមនុស្ស ។ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលមាននាយកដ្ឋានចំណុះចំនួន ៣ និង មជ្ឈមណ្ឌលចំនួន ១ គឺ
  - នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស
  - នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ
  - នាយកដ្ឋានហិរញ្ញវត្ថុ
  - មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម

- **នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ទទួលបន្ទុក**
  - សម្របសម្រួល សកម្មភាពគ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយនឹងអង្គភាពមូលដ្ឋានក្រោមឱវាទ
  - គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង
  - សរុប និងធ្វើរបាយការណ៍ការងារ សកម្មភាពផ្សេងៗ របស់ក្រសួង
  - រៀបចំសៀវភៅស្តីពីនិតិវិធីរដ្ឋបាល និងគ្រប់គ្រងបណ្ណាល័យ
  - គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយក្រសួងមុខងារសាធារណៈ
  - រៀបចំលិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព
  - រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ
  - ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
  - រៀបចំការងារ បៀវត្សពលកម្ម ប្រាក់កម្រៃ និងរបបធានារ៉ាប់រងសង្គម
  - កសាងផែនការបណ្តុះបណ្តាលមន្ត្រីរាជការ រយៈពេលវែង និងខ្លីក្នុងប្រទេស និងក្រៅប្រទេស
  - សហការជាមួយគ្រឹះស្ថានសិក្សាសាធារណៈនានា ដើម្បីចូលរួមកសាងកម្មវិធីសិក្សា និងសកម្មភាពរបស់អង្គភាពទាំងនោះសម្រាប់បណ្តុះបណ្តាលស្របទៅតាមតម្រូវការអភិវឌ្ឍន៍នៃសង្គម
  - លើកសំណើបង្កើត ឬរំសាយអង្គភាពនានា រៀបចំតួនាទីភារកិច្ចកែសម្រួលរចនាសម្ព័ន្ធតាមស្ថានភាពជាក់ស្តែងតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន

- **នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុក**
  - រៀបចំចងក្រង គ្រប់គ្រងប្រព័ន្ធទិន្នន័យ ស្ថិតិរបស់ក្រសួង និងលើកផែនការអភិវឌ្ឍន៍ជាទូទៅរយៈពេលខ្លី មធ្យម និងវែង លើគ្រប់ផ្នែកទាំងអស់
  - រៀបចំកសាងកម្មវិធីវិនិយោគសាធារណៈ កម្មវិធីចំណាយសាធារណៈ និងកម្មវិធីអភិវឌ្ឍន៍គោលដៅអាហារូបត្ថម្ភ
  - ធ្វើកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេស លើវិស័យអភិវឌ្ឍន៍ធនធានទឹក និងឧតុនិយម
  - សម្របសម្រួល ជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្តន៍

- រៀបចំឯកសារ កិច្ចព្រមព្រៀង ឬពិធីសារនៃកិច្ចសហប្រតិបត្តិការ រវាងក្រសួងធនធានទឹក និងឧតុនិយម ជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការអន្តរជាតិ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ

▪ **នាយកដ្ឋានហិរញ្ញវត្ថុ ទទួលបន្ទុក**

- ប្រមូលផ្តុំតម្រូវការ លើកគម្រោងថវិកាក្រសួង ធ្វើកម្មវិធីចំណាយ និងតាមដានរំលឹកពីការប្រតិបត្តិ
- សម្របសម្រួលជំពូកថវិកា និងរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- ធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ គ្រឿងបន្លាស់សម្រាប់យានយន្តរបស់រដ្ឋ ដែលប្រគល់ជូនក្រសួង
- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាពនានាក្រោមឱវាទក្រសួង
- កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ
- គ្រប់គ្រងព័ត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- គ្រប់គ្រងបន្ទុកគណនី របស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ
- ប្រមូលចំណូល ឲ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុបង់ចូលថវិការដ្ឋ

▪ **មជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម ទទួលបន្ទុក**

- សិក្សាតម្រូវការអភិវឌ្ឍន៍ធនធានមនុស្ស សម្រាប់វិស័យធនធានទឹក និងឧតុនិយម
- ធ្វើការបណ្តុះបណ្តាល និងវិក្រឹត្យការ ដល់មន្ត្រីបច្ចេកទេសទាំងថ្នាក់កណ្តាល និងរាជធានី-ខេត្ត លើវិស័យធនធានទឹក និងឧតុនិយម
- សិក្សាស្រាវជ្រាវបច្ចេកវិទ្យា និងធ្វើទំនើបកម្មលើប្រព័ន្ធធារាសាស្ត្រ
- ផ្សព្វផ្សាយនូវបច្ចេកវិទ្យាថ្មី និងទំនើបកម្មលើវិស័យធនធានទឹក និងឧតុនិយម
- រៀបចំចងក្រងឯកសារសៀវភៅបច្ចេកទេស និងព័ត៌មាន ដែលពាក់ព័ន្ធនឹងវិស័យធនធានទឹក និងឧតុនិយម
- ផ្តល់ការប្រឹក្សាបច្ចេកទេសទៅដល់មន្ត្រីបច្ចេកទេសមន្ទីររាជធានី-ខេត្ត និងការដ្ឋានសាងសង់ប្រព័ន្ធធារាសាស្ត្រ ឧតុនិយម
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន

• **អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស** ទទួលបន្ទុកគ្រប់គ្រងធ្វើអាជីវកម្ម ត្រួតពិនិត្យណែនាំផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងសម្របសម្រួលនូវរាល់ការងារដែលពាក់ព័ន្ធនឹងទឹក រួមទាំងទឹកលើដីទាំងទឹកក្រោមដី និងទឹកលើអាកាស

អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេសមាននាយកដ្ឋានចំណុះចំនួន ៧ គឺ

▪ នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក
▪ នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ
▪ នាយកដ្ឋានឧតុនិយម
▪ នាយកដ្ឋានធារាសាស្ត្រកសិកម្ម

- នាយកដ្ឋានទឹកស្អាត និងអនាម័យ
- នាយកដ្ឋានវិស្វកម្ម
- នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក

▪ **នាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក ទទួលបន្ទុក**

- រៀបចំឯកសារ និងអនុវត្តគម្រោងផែនការជាយុទ្ធសាស្ត្របម្រើដល់កិច្ចអភិវឌ្ឍន៍ពហុបំណង វារីអគ្គិសនី ត្រួតពិនិត្យជំនន់ ស្រោចស្រព ... ។ល។ លើកលែងតែគម្រោងណាបម្រើឲ្យការផលិតអគ្គិសនីជាបំណងចំបង
- គ្រប់គ្រងតំបន់ផ្ទៃរងទឹកភ្លៀង និងកសាងកម្មវិធីចាត់ចែងប្រើប្រាស់ទឹក ដើម្បីធានាដល់ការធ្វើអាជីវកម្ម និងអភិរក្សធនធានទឹក ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព
- ស្រាវជ្រាវកសាងគោលនយោបាយ ច្បាប់ បទបញ្ញត្តិ និងបណ្តាលិខិតបទដ្ឋាននានា បម្រើដល់ការអភិរក្សធនធានទឹក ប្រកបដោយនិរន្តរភាពជូនរាជរដ្ឋាភិបាល ពិនិត្យ សម្រេច និងធ្វើការណែនាំ ផ្សព្វផ្សាយ ត្រួតពិនិត្យលើការអនុវត្ត
- ធ្វើអធិការកិច្ចបច្ចេកទេស លើបណ្តាសំណង់ដែលពាក់ព័ន្ធនឹងធនធានទឹក
- ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ ដើម្បីមានវិធានការកែលម្អ ផ្សព្វផ្សាយ និងចងក្រងឯកសារបច្ចេកទេស ដើម្បីបម្រើដល់ការអភិវឌ្ឍន៍

▪ **នាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ ទទួលបន្ទុក**

- រៀបចំកសាងគម្រោងដំឡើងស្ថានីយជលសាស្ត្រលើទីតាំងប្រភពទឹកសំខាន់ៗបម្រើដល់ការអភិវឌ្ឍន៍វិស័យធនធានទឹក
- រៀបចំកសាងគម្រោងផែនការរយៈពេលខ្លី មធ្យម និងវែងលើការងារការហូរច្រោះ កំណកដី និងច្រាំងទន្លេ
- ធ្វើការស្រាវជ្រាវតាមដាននូវរាល់របបជលសាស្ត្រទាំងលើដី ទាំងក្រោមដីដោយគ្រប់គ្រងដំឡើងស្ថានីយជលសាស្ត្រប្រមូលទិន្នន័យបម្រើដល់វិស័យនានា
- អនុវត្តការងារវាស់កំពស់ទឹក ធារទឹក កករទឹក
- អនុវត្តលើការពិនិត្យគុណភាពទឹក នៅតាមស្ថានីយជលសាស្ត្រសំខាន់ៗ
- សិក្សាស្រាវជ្រាវបាតុភូតជលសាស្ត្រ គំរូជលសាស្ត្រជលគណនា និងសក្តានុពលទឹកលើដី និងក្រោមដី
- គ្រប់គ្រង និងផ្លាស់ប្តូរព័ត៌មានជលសាស្ត្រព្រមទាំងធ្វើការព្យាករណ៍ និងជូនដំណឹងជាមុននូវគ្រោះទឹកជំនន់ កង្វះខាតទឹក ដែលអាចកើតមានឡើង ដើម្បីមានវិធានការទាន់ពេលវេលា
- រៀបចំប្រព័ន្ធព័ត៌មានភូមិសាស្ត្រដែលពាក់ព័ន្ធទៅនឹងការវិវត្តន៍ នៃវិស័យធនធានទឹក និងឧតុនិយម

▪ **នាយកដ្ឋានឧតុនិយម ទទួលបន្ទុក**

- រៀបចំកសាងគម្រោងផែនការរយៈពេលខ្លី មធ្យម និងវែង បម្រើដល់ការងារស្តារ និងអភិវឌ្ឍន៍វិស័យឧតុនិយម ក្នុងក្របខណ្ឌទូទាំងប្រទេសដំឡើង និងគ្រប់គ្រងស្ថានីយឧតុនិយមក្នុងក្របខណ្ឌទូទាំងប្រទេស

- ធ្វើការសង្កេតតាមដាននូវអាកាសធាតុទាំងលើផ្ទៃដី ទាំងក្នុងលំហអាកាសសំដៅបម្រើឲ្យដល់គ្រប់វិស័យដែលពាក់ព័ន្ធ
- ប្រមូល និងផ្លាស់ប្តូរទិន្នន័យឧតុនិយម ក្នុង និងក្រៅប្រទេស ដើម្បីធ្វើការវិភាគកសាងឯកសារមូលដ្ឋាន
- ធ្វើការព្យាករណ៍រយៈពេលខ្លី វែង សម្រាប់តម្រូវការរបស់ស្ថាប័ននានា និងជូនដំណឹងជាមុននូវគ្រោះធម្មជាតិ ដែលអាចកើតមានឡើងជាយថាហេតុ ដើម្បីមានវិធានការទាន់ពេលវេលា
- ធ្វើការផ្លាស់ប្តូរ និងស្រាវជ្រាវបច្ចេកវិទ្យាទំនើបៗ នៃវិស័យឧតុនិយម ក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពឧតុនិយម នៅព្រះរាជាណាចក្រកម្ពុជា និងរបាយការណ៍ផ្សេងៗទៀត ដែលចាំបាច់សម្រាប់រាជរដ្ឋាភិបាល ក្នុងការបំពេញកាតព្វកិច្ច និងទទួលខុសត្រូវដែលទាក់ទង និងអនុសញ្ញាអន្តរជាតិ
- គ្រប់គ្រង និងសម្របសម្រួលកិច្ចសហប្រតិបត្តិការលើការងារពាក់ព័ន្ធនឹងវិស័យឧតុនិយមកម្ពុជា ជាមួយភ្នាក់ងារសហប្រជាជាតិ និងអង្គការឧតុនិយម នៃបណ្តាប្រទេសក្នុងនាមអចិន្ត្រៃយ៍ នៃអង្គការឧតុនិយមពិភពលោកប្រចាំនៅកម្ពុជា

▪ **នាយកដ្ឋានធារាសាស្ត្រកសិកម្ម ទទួលបន្ទុក**
- រៀបចំកសាងគម្រោងផែនការរយៈពេលខ្លី មធ្យម និងវែង សម្រាប់ការងារស្តារ និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រតូច មធ្យម និងធំ
- ចាត់ចែងគ្រប់គ្រងលើកិច្ចដំណើរការនិងថែទាំប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹកដែលមានស្រាប់
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃ ជាប្រចាំនូវសកម្មភាពធ្វើអាជីវកម្មទឹកក្រោមដី បម្រើឲ្យដល់ការស្រោចស្រពកសិកម្ម
- រៀបចំគម្រោងផែនការអភិវឌ្ឍន៍តំបន់ការពារទឹកប្រៃ នៅតំបន់ឆ្នេរសមុទ្រ
- ចាត់ចែងលើកិច្ចដំណើរការ និងថែទាំរាល់ស្ថានីយបូមទឹក ម៉ាស៊ីនបូមទឹកប្រភេទធំ និងមធ្យម
- បំផុស អប់រំ ចងក្រង និងណែនាំដល់សហគមន៍កសិករប្រើប្រាស់ទឹក និងតាមដានការអនុវត្តន៍ជាប្រចាំ
- ចាត់ចែង ត្រួតពិនិត្យ និងដឹកនាំការងារអន្តរាគមន៍ បង្ការទប់ទល់គ្រោះធម្មជាតិ ដូចជាទឹកជំនន់ និងរាំងស្ងួត

▪ **នាយកដ្ឋានទឹកស្អាត និងអនាម័យ ទទួលបន្ទុក**
- ធ្វើការសិក្សាប្រភពទឹកលើដី និងទឹកក្រោមដី
- ធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃ ព្រមទាំងរៀបចំគម្រោងផែនការរយៈពេលខ្លី មធ្យម វែងលើការអភិវឌ្ឍនូវប្រភពទឹកដែលបម្រើដល់ការផលិតទឹកស្អាត និងតាមដានព្រមទាំងត្រួតពិនិត្យ និងការអនុវត្ត
- រៀបចំគម្រោងផែនការរយៈពេលខ្លី មធ្យម និងវែងលើការអភិវឌ្ឍន៍បញ្ចេញ ទឹកសំណល់ពីរាជធានី ទីក្រុង ទីប្រជុំជន និងគ្រប់គ្រងតាមដាន ព្រមទាំងត្រួតពិនិត្យការអនុវត្ត

- ធ្វើការសិក្សាស្រាវជ្រាវ និងតាមដានវាយតម្លៃជាប្រចាំនូវគុណភាពទឹក ប្រភពទឹកលើដី និង ក្រោមដីដែលបាន និងកំពុងយកមកប្រើប្រាស់

▪ **នាយកដ្ឋានវិស្វកម្ម ទទួលបន្ទុក**

- សិក្សា គ្រោងប្លង់ និងសាងសង់នូវរាល់ប្រភេទសំណង់ដែលមានការពាក់ព័ន្ធនឹងធនធានទឹក
- គ្រប់គ្រងឧបករណ៍ និងគ្រឿងចក្រដែលបម្រើដល់ការសិក្សាគ្រោងប្លង់ និងសាងសង់
- អនុវត្តលើការពិនិត្យគុណភាពដី បម្រើដល់ការសាងសង់
- សិក្សាស្រាវជ្រាវនូវគំរូសំណង់ បទដ្ឋានសំណង់ និងបច្ចេកវិទ្យាទំនើបៗដែលបម្រើឲ្យដល់សេដ្ឋកិច្ចជាតិ និងធានានិរន្តរភាពក្នុងការប្រើប្រាស់

▪ **នាយកដ្ឋានសហគមន៍កសិករប្រើប្រាស់ទឹក ទទួលបន្ទុក**

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍បន្តលើប្រព័ន្ធធារាសាស្ត្រឲ្យមាននិរន្តរភាពស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល
- សិក្សាស្រាវជ្រាវ និងចងក្រងនូវព័ត៌មាន និងទិន្នន័យទាំងអស់របស់ប្រព័ន្ធធារាសាស្ត្រក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីកំណត់ និងបង្កើតឡើងនូវមូលដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រច្បាស់លាស់បង្កលក្ខណៈងាយស្រួលដល់ការងារគ្រប់គ្រង និងកិច្ចអភិវឌ្ឍន៍បន្ត
- លើកទិសដៅផែនការរយៈពេលខ្លី មធ្យម និងវែង ក្នុងការគ្រប់គ្រងកិច្ចដំណើរការ និងការថែទាំប្រព័ន្ធធារាសាស្ត្រទាំងអស់ដើម្បីបម្រើដល់សេដ្ឋកិច្ចជាតិ និងបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- គ្រប់គ្រង ត្រួតពិនិត្យនូវរាល់ការប្រើប្រាស់ លើវិស័យប្រព័ន្ធធារាសាស្ត្រដោយផ្ទាល់ និងប្រយោលប្រកបដោយនិរន្តភាព និងកាត់បន្ថយឲ្យបានជាអតិបរមានូវគ្រោះមហន្តរាយដែលអាចកើតមានឡើងជាយថាហេតុ
- រៀបចំតាក់តែងច្បាប់លិខិតបទដ្ឋានគតិយុត្តិផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងថែទាំកិច្ចដំណើរការ និងអភិវឌ្ឍន៍បន្តលើប្រព័ន្ធធារាសាស្ត្រ ព្រមទាំងតាមដានលើការអនុវត្ត
- ផ្តល់ការគាំទ្រ និងការណែនាំបច្ចេកទេសជាចាំបាច់ដល់ឯកជនអង្គការវិជ្ជាជីវៈសហគមន៍កសិករប្រើប្រាស់ទឹក និងជាប្រជាពលរដ្ឋទូទៅ ដែលមានការពាក់ព័ន្ធក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រឲ្យបានសមស្រប និងមាននិរន្តរភាព
- ពង្រីកការស្រាវជ្រាវ ការអនុវត្ត និងបញ្ចូលនូវបច្ចេកវិទ្យាទំនើបៗលើការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ដោយមានការចូលរួមពីអ្នកទទួលផល និងធ្វើការបណ្តុះបណ្តាល កែលម្អ និងផ្សព្វផ្សាយដល់មន្ត្រីរាជការ និងសមាជិកសហគមន៍កសិកប្រើប្រាស់ទឹក ក្នុងក្របខណ្ឌទូទាំងប្រទេស
- ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីធានានិរន្តរភាពរបស់ប្រព័ន្ធធារាសាស្ត្រ ក្នុងក្របខណ្ឌទូទាំងប្រទេស

▪ **អង្គភាពមូលដ្ឋាន:** មន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត ចំនួន ២៥ ។

## ខ-អាជ្ញាធរទន្លេសាប ៖

### ខ.១. មុខងារ និងភារកិច្ច

អាជ្ញាធរទន្លេសាប គឺជាស្ថាប័នថ្មីមួយ និងជាសេនាធិការបន្ថែមជួយដល់រាជរដ្ឋាភិបាលកម្ពុជាមាន បេសកកម្មការងារក្នុងការសម្របសម្រួលដល់ **ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ តំបន់ទន្លេសាប** ដូចបាន កំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ និងព្រះរាជក្រឹត្យ លេខ នស/រកត/០៣១០/២៥៨ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១០ ស្តីពី ការកែសម្រួលមាត្រា ៣ មាត្រា ៥ មាត្រា ៦ មាត្រា ៩ មាត្រា ១០ និងមាត្រា ១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ។

ជាមួយនឹងបេសកកម្មការងារ និងតួនាទីភារកិច្ចស្នូលក្នុងការទទួលខុសត្រូវ ចំពោះមុខរាជរដ្ឋាភិបាល អាជ្ញាធរទន្លេសាប បានរៀបចំបង្កើតឡើងនូវ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដូចមានកំណត់ក្នុង អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ១៦៦ អនក្របក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩ សម្រាប់ដំណើរការ ការងារប្រចាំថ្ងៃ និងចាត់ចែងទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាងក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់ការ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព ។

យោងតាមមាត្រា ២ ជំពូកទី ២ នៃអនុក្រឹត្យ ដែលចែងពីតួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- ទទួលបន្ទុកដឹកនាំ ចាត់ចែង និងសម្របសម្រួលរាល់សកម្មភាពការងារប្រចាំថ្ងៃរបស់អាជ្ញាធរ ទន្លេសាប
- សិក្សាស្រាវជ្រាវ អំពីសក្តានុពលធនធានធម្មជាតិ ដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវ ត្រួតពិនិត្យ វាយតម្លៃ និងតាមដាន លើការធ្វើអាជីវកម្ម និងការប្រើប្រាស់ ធនធាន ធម្មជាតិដែលមានក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យ និងវិភាគនូវរាល់ព័ត៌មាន និងសកម្មភាពជាក់ស្តែង ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រ ចំពោះមុខ និងយូរអង្វែង ជូនរាជរដ្ឋាភិបាល ក្នុងការកំណត់ទិសដៅគោលដៅបម្រើដល់កិច្ចអភិវឌ្ឍន៍ និងអភិរក្ស
- រៀបចំគោលនយោបាយ ទស្សនៈវិស័យ បេសកកម្មរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួល និងសហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា លើរាល់សកម្មភាព ទាក់ទង នឹងការ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព
- សហការ ជាមួយបណ្តាក្រសួងស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធីគម្រោងអភិរក្ស អភិវឌ្ឍន៍ផ្សេងៗ ដែលមាននៅក្នុង តំបន់ទន្លេសាប
- រៀបចំចងក្រងឯកសារទិន្នន័យ ព័ត៌មាន ដើម្បីអប់រំផ្សព្វផ្សាយ
- ធ្វើរបាយការណ៍ប្រចាំខែ ឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរទន្លេសាប
- អនុវត្តន៍ភារកិច្ចផ្សេងៗ ដែលប្រធានអាជ្ញាធរទន្លេសាប ប្រគល់ជូន

## ខ.២. រចនាសម្ព័ន្ធ

យោងតាមអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងមាត្រា ៣ ជំពូក ៣ ដែលចែងពីរចនាសម្ព័ន្ធ និងការគ្រប់គ្រង គឺមាននាយកដ្ឋានចំនួន ០៤ អមដោយការិយាល័យចំនួន ១៤ និងបានកំណត់ពីតួនាទី ភារកិច្ចទទួលខុសត្រូវតាមនាយកដ្ឋាន និងការិយាល័យនីមួយៗ ដូចមានចែងក្នុងប្រកាសលេខ ០២៥ អទស ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់ការិយាល័យចំណុះបណ្តានាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ។ នាយកដ្ឋាន និងការិយាល័យស្ថិតក្រោមឱវាទ រួមមាន ៖

- **នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ** មានតួនាទី និងភារកិច្ចរួមមាន ៖
  - ទទួលខុសត្រូវលើសេវាកម្មរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាល ជូនគ្រប់អង្គភាពនៅក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃ អ.ទ.ស
  - ទទួលខុសត្រូវលើការងារសំណុំលិខិតឯកសារលិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់ ការងារតម្កល់ឯកសារ ពិធីការ សណ្តាប់ធ្នាប់ និងអនាម័យ
  - គ្រប់គ្រងឯកសារ និងក្របខណ្ឌមន្ត្រីរាជការ បុគ្គលិក និងរៀបចំបៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ
  - គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ និងបញ្ជីសារពើភ័ណ្ឌរបស់ អ.ទ.ស
  - រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស
  - រៀបចំគម្រោងផែនការថវិកា សម្ភារ និងមធ្យោបាយនានា របស់ អ.ទ.ស
  - រៀបចំគោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង សម្រាប់បម្រើដល់ការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប ប្រកបដោយនិរន្តរភាព
  - តាមដាន វាយតម្លៃ ប្រសិទ្ធភាព នៃការអនុវត្តផែនការសកម្មភាព
  - សម្របសម្រួល សហការ ជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ
  - ធ្វើកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីគៀងគរកជំនួយ
  - រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត
  - អនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ទ.ស ប្រគល់ជូន
- **នាយកដ្ឋានធនធានធម្មជាតិ**មានតួនាទី និងភារកិច្ចរួមមាន ៖
  - សិក្សាស្រាវជ្រាវពីសក្តានុពលទឹក និងការប្រែប្រួលអាកាសធាតុ ព្រមទាំងកត្តាផ្សេងៗទៀតដែលនាំឲ្យប៉ះពាល់ដល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
  - សិក្សាស្រាវជ្រាវពីធនធានមច្ឆជាតិ ធនធានព្រៃលិចទឹក ធនធានរ៉ែ និងធនធានជីវចម្រុះផ្សេងទៀតដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
  - សិក្សាស្រាវជ្រាវពីសក្តានុពលទឹក ដី ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
  - ពិនិត្យ និងផ្តល់យោបល់ លើការស្នើសុំប្រើប្រាស់នូវរាល់ធនធានធម្មជាតិ ដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
  - អនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ទ.ស ប្រគល់ជូន
- **នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស**មានតួនាទី និងភារកិច្ចរួមមាន ៖
  - តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការធ្វើអាជីវកម្មធនធានទឹក ដី ធនធានមច្ឆជាតិ ធនធានរ៉ែ ធនធានជីវចម្រុះផ្សេងទៀតដែលមានក្នុងតំបន់ទន្លេសាបនិងតំបន់ពាក់ព័ន្ធ

- តាមដានត្រួតពិនិត្យវាយតម្លៃ និងផ្តល់យោបល់លើការប្រើប្រាស់រាល់ធនធានធម្មជាតិដែលមាននៅក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ប្រមូលទិន្នន័យព័ត៌មានវិភាគដើម្បីកំណត់តំបន់អភិរក្សធនធានទឹក ព្រៃលិចទឹក មច្ឆជាតិ រ៉ែ និងធនធានជីវចម្រុះផ្សេងទៀត ដើម្បីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា
- រៀបចំផែនទី សម្រាប់បម្រើដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ទ.ស ប្រគល់ជូន

- **នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**មានតួនាទី និងភារកិច្ចរួមមាន ៖
- ប្រមូលចងក្រង និងសិក្សាស្វែងយល់នូវរាល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលមានការពាក់ព័ន្ធ
- ទទួលពាក្យបណ្តឹង និងសម្របសម្រួលនូវរាល់វិវាទនានា ដែលកើតឡើងក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចូលរួមផ្តល់យោបល់លើការរៀបចំសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗដែលមានការពាក់ព័ន្ធ
- រៀបចំពិធីសារ អនុស្សរណៈ កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ
- ផ្សព្វផ្សាយព័ត៌មាន ទាំងវិជ្ជមាន ទាំងអវិជ្ជមាន សំដៅបម្រើឲ្យកិច្ចអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
- សហការ ជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល
- អនុវត្តន៍ភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ អ.ទ.ស ប្រគល់ជូន

## គ-គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ៖

### គ.១. មុខងារ និងភារកិច្ច

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គ.ជ.ទ.ម.ក) ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គប្រកបដោយនិរន្តភាព ។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក៏ដូចជាគណៈកម្មាធិការ ជាតិទន្លេមេគង្គនៃប្រទេសជាសមាជិកផ្សេងទៀតដែរ គឺមានតួនាទីក្នុងការសម្របសម្រួលក្នុងក្របខណ្ឌនៃប្រទេសរៀងៗខ្លួន ក្នុងការអនុវត្តឲ្យមានប្រសិទ្ធិភាព និងប្រកបដោយជោគជ័យនូវកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ និងនីតិវិធីស្តីពីការប្រើប្រាស់ទឹក របស់គណៈកម្មការទន្លេមគង្គ (MRC) និងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ២០១៦-២០២០ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ វិមជ្ឈការមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេមេគង្គដោយអនុលោមតាមការប្តេជ្ញាចិត្តរបស់ប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិករបស់គណៈកម្មការទន្លេមេគង្គក្នុងការធានាស្វយភាពហិរញ្ញវត្ថុទាំងស្រុងចាប់ពីឆ្នាំ ២០៣០ តទៅ និង គម្រោងកម្មវិធីកិច្ចសហប្រតិបត្តិការតំបន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ។

### គ.២. រចនាសម្ព័ន្ធ

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការដែលមាននាយកដ្ឋាន ចំនួន ០៥ និងលេខាធិការដ្ឋានចំនួន ០១ ស្ថិតនៅក្រោមឱវាទផ្ទាល់ដែលអង្គភាពខាងលើនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- **អគ្គលេខាធិការដ្ឋាន ៖**
  - ជាសេនាធិការក្នុងការដឹកនាំ ចាត់ចែង និងសម្របសម្រួលរាល់សកម្មភាពប្រចាំថ្ងៃរបស់ គ.ជ.ទ.ម.ក
  - ជាសេនាធិការឲ្យ គ.ជ.ទ.ម.ក ក្នុងកិច្ចសហការនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រាជធានី-ខេត្តពាក់ព័ន្ធ បណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ-អន្តរជាតិផ្សេងៗទៀតលើរាល់សកម្មភាពក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
  - ធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ លើរាល់សកម្មភាពពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ស្រាវជ្រាវ និងវិភាគទិន្នន័យ ព័ត៌មានពាក់ព័ន្ធនឹងអាងទន្លេមេគង្គកម្ពុជា
  - លើកគម្រោង និងកម្មវិធីការងារជាក់ជូនគណៈកម្មការទន្លេមេគង្គ ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិនានា និងប្រភពផ្សេងៗទៀត ដើម្បីរកជំនួយ
  - លើកគម្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាពរបស់ គ.ជ.ទ.ម.ក
  - ណែនាំ តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តការងាររបស់បណ្តាអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក
  - ត្រួតពិនិត្យ តាមដានសកម្មភាពការងាររបស់គណៈកម្មការទន្លេមេគង្គដែលសហការជាមួយក្រសួង-ស្ថាប័នជំនាញ
- **នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ៖**
  - ទទួលខុសត្រូវលើកិច្ចការរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាលជូនគ្រប់អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក
  - ទទួលខុសត្រូវការងារសំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់
  - ការតម្កល់ឯកសារ ពិធីការ ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ
  - រៀបចំគម្រោងផែនការថវិកា សម្ភារៈបរិក្ខារ និងមធ្យោបាយការងារប្រចាំឆ្នាំរបស់ គ.ជ.ទ.ម.ក
  - ប្រតិបត្តិថវិកាទៅតាមគោលការណ៍លទ្ធកម្ម និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
  - គ្រប់គ្រង និងថែរក្សាអចលនទ្រព្យ ចលនទ្រព្យ
  - ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌរបស់ គ.ជ.ទ.ម.ក
  - រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
  - ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
  - បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ គ.ជ.ទ.ម.ក
- **នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ៖**
  - ទទួលបន្ទុកការងារគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិក
  - រៀបចំក្របខណ្ឌបៀវត្ស គ្រឿងឥស្សរិយយសការងារ ការលើកទឹកចិត្ត និងការឧបត្ថម្ភផ្សេងៗ
  - រៀបចំ និងតម្កល់ឯកសារពាក់ព័ន្ធការងាររបស់មន្ត្រីរាជការ និងបុគ្គលិក
  - ពិនិត្យ វាយតម្លៃលើការអនុវត្តការងាររបស់មន្ត្រីរាជការ និងបុគ្គលិក
  - សម្របសម្រួលការផ្សព្វផ្សាយដំណឹងជ្រើសរើសមន្ត្រី និងបុគ្គលិក
  - រៀបចំផែនការរួមសម្រាប់ការអភិវឌ្ឍធនធានមនុស្ស រយៈពេលខ្លី មធ្យម និងវែង
  - រៀបចំគម្រោងថវិកា សម្ភារៈ និងមធ្យោបាយសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស
  - សហការ សម្របសម្រួលក្នុងការអនុវត្តនិងគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល ធនធានមនុស្ស
  - រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
  - ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ

- **នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ ៖**
  - រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីសម្រេចបាននូវគោលដៅរួមរបស់ គ.ជ.ទ.ម.ក
  - ប្រមូលផ្តុំ និងធ្វើសំយោគលទ្ធផលនៃការសិក្សាលើធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គដើម្បីរៀបចំយុទ្ធសាស្ត្រ និងផែនការសម្រាប់ការអភិវឌ្ឍរយៈពេលខ្លី មធ្យម និងវែង
  - ស្រាវជ្រាវ ប្រមូលផ្តុំ និងចងក្រងបណ្តាគោលការណ៍ បទដ្ឋានគតិយុត្តិ និងឯកសារបច្ចេកទេសនានាសម្រាប់បម្រើដល់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
  - សហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធក្នុងការអនុវត្តគម្រោង និងកម្មវិធីនានាលើការងាររៀបចំផែនការ និងយុទ្ធសាស្ត្រក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
  - ពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
  - ជាសេនាធិការឲ្យអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ធ្វើទំនាក់ទំនង សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងប្រភពផ្សេងៗទៀត ដើម្បីគៀងគររកជំនួយ
  - រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
  - ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- **នាយកដ្ឋានបណ្តាគម្រោង និងកម្មវិធី ៖**
  - សហការ សម្របសម្រួលក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
  - សហការ សម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវនិងរៀបចំគម្រោងកម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
  - សហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីសិក្សាស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់បរិស្ថានក្នុងការប្រើប្រាស់ធនធានទឹកនិងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
  - សហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោង និងកម្មវិធីនានាក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
  - វាយការណ៍រាល់សកម្មភាពអនុវត្តការងារគ្រប់គ្រង និងវាយតម្លៃគម្រោង និងកម្មវិធីក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី ជូនអគ្គលេខាធិការ
  - រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
  - ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការ
- **នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង ៖**
  - ស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធបណ្តាគោលការណ៍ បទដ្ឋានគតិយុត្តិនានា និងឯកសារបច្ចេកទេស សម្រាប់បម្រើដល់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ

- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារ និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មាន
- រៀបចំបង្កើត និងគ្រប់គ្រងគេហទំព័ររបស់ គ.ជ.ទ.ម.ក
- អភិវឌ្ឍន៍ គ្រប់គ្រង និងកសាងសមត្ថភាពលើការប្រើប្រាស់ឧបករណ៍បច្ចេកទេសសម្រាប់វិភាគ និងវាយតម្លៃលើគម្រោងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- គ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសមិទ្ធផល និងសកម្មភាពការងាររបស់ គ.ជ.ទ.ម.ក
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការ

- ***លេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប ៖***
  - រៀបចំផែនការយុទ្ធសាស្ត្រ និងយន្តការដើម្បីសំរេចគោលបំណងសំខាន់ៗរបស់បបនីយជីវីមណ្ឌលបឹងទន្លេសាប
  - បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានចម្រុះសម្រាប់បបនីយជីវីមណ្ឌលបឹងទន្លេសាបនិងយន្តការផ្លាស់ប្តូរទិន្នន័យព័ត៌មានក្នុងចំណោមស្ថាប័នពាក់ព័ន្ធ
  - តាមដានពិនិត្យវាយតម្លៃ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពបបនីយជីវីមណ្ឌលបឹងទន្លេសាបក្នុងរយៈពេលពី ៤ ទៅ ១០ ឆ្នាំម្តងតាមតម្រូវការចាំបាច់
  - សម្របសម្រួល និងសហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធដើម្បីពិនិត្យឡើងវិញនូវច្បាប់បទប្បញ្ញត្តិនានា ដើម្បីធ្វើអនុសាសន៍លើកស្ទួយការគ្រប់គ្រង់បបនីយជីវីមណ្ឌលបឹងទន្លេសាបប្រកបដោយនិរន្តរភាព
  - សម្របសម្រួលរៀបចំប្រព័ន្ធសិក្សាស្រាវជ្រាវ និងឃ្លាំមើលជីវចម្រុះ
  - សម្របសម្រួលជាមួយនឹងក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀតក្នុងគោលបំណងរៀបចំលើកគម្រោងផែនការដើម្បីរកជំនួយពីរាជរដ្ឋាភិបាល និងអង្គការអន្តរជាតិ
  - រៀបចំរបាយការណ៍ប្រចាំត្រីមាសនិងប្រចាំឆ្នាំអំពីសកម្មភាពភាពរបស់លេខាធិការដ្ឋាន ។

## ២-លទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៩ ( ធៀបសូចនាករដែលបានកំណត់ ) ៖

ក្រសួងបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ។ ជាក់ស្តែង សមិទ្ធិផលដែលសម្រេចបានមានដូចខាងក្រោម ៖

### ក-ក្រសួងធនធានទឹក និងឧតុនិយម ៖

#### ១.ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក (ក្នុងយុទ្ធសាស្ត្រទី១ / កម្មវិធីទី១ របស់ក្រសួង)

#### ១.១.ការស្តារ និងការសាងសង់ប្រព័ន្ធធារាសាស្ត្រ

ប្រទេសកម្ពុជា ជាប្រទេសសំបូរទៅដោយធនធានទឹក និងប្រព័ន្ធទន្លេ ដូចជាទន្លេមេគង្គ បឹងទន្លេសាប ទន្លេសាប និងដៃទន្លេនានា តែផ្ទៃដីទទួលការស្រោចស្រពនៅមានកម្រិតនៅឡើយ ។ ក្រសួងធនធានទឹក និងឧតុនិយម បានជួសជុល-ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ និងកិច្ចដំណើរការថែទាំ មានដូចខាងក្រោម៖

**ក-ជួសជុល-ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ដើម្បីបង្កើនលទ្ធភាពស្រោចស្រព**

បានធ្វើការជួសជុល-ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រទាំងតូចទាំងធំនៅទូទាំងប្រទេស ក្នុងឆ្នាំ ២០១៩ សម្រេចបាន **៥២ គម្រោង** ដែលបង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវ សរុបចំនួន

**៣៣.០៦៣ ហ.ត** ក្នុងនោះ (ស្រូវរដូវវស្សា **២២.៣១៥ ហ.ត** និងស្រូវរដូវប្រាំង **១០.៧៤៨ ហ.ត**) និងស្រោចស្រពដំណាំរួមផ្សំបាន **៩១២ហ.ត** ។

**ខ-កិច្ចដំណើរការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំ និងខួប ដើម្បីរក្សានិរន្តរភាពស្រោចស្រព**

បានកិច្ចដំណើរការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំ និងខួបទាំងតូចទាំងធំនៅទូទាំងប្រទេសក្នុងឆ្នាំ ២០១៩ សម្រេចបាន **១៩៩ គម្រោង** ដែលរក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុបចំនួន **៤៩៩.៧៤០ ហ.ត** ក្នុងនោះ (ស្រូវរដូវវស្សា **៤០៩.២៦៧ ហ.ត** និងស្រូវរដូវប្រាំង **៩០.៤៧៣ ហ.ត**) និងស្រោចស្រពដំណាំរួមផ្សំបាន **១.៩២៤ ហ.ត** ។

### ១.២.ការជួសជុល-ថែទាំសំណង់សិល្បការ

ក្រសួង និងមន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត បានធ្វើការជួសជុល-ថែទាំ សំណង់សិល្បការតាមបណ្ដាប្រព័ន្ធធារាសាស្ត្រ ហើយសម្រេចបានរួមមាន៖ សំណង់ទ្វារទឹក សរុបចំនួន **៣៤ កន្លែង** សំណង់លូទឹក សរុបចំនួន **៤២ កន្លែង** សំណង់ស្នាក់ទឹក សរុបចំនួន **៣៧ កន្លែង** និងសំណង់បង្ហៀរទឹក សរុបចំនួន **៣ កន្លែង** ។

### ១.៣.ការជួសជុល-ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម

#### ១.៣.១.ការជួសជុល-ថែទាំទំនប់

បានធ្វើការជួសជុលថែទាំទំនប់នៅតាមបណ្ដាខេត្តសរុបចំនួន **១៥ កន្លែង** ប្រវែង **២៦.៧២៤ ម** សាច់ដីសរុបចំនួន **១.០៤៤ ម៣** ។

#### ១.៣.២.ការងារជីក-ស្ដារប្រឡាយ

បានធ្វើការងារជីក-ស្ដារប្រឡាយ នៅតាមបណ្ដាខេត្តសរុបចំនួន **៥២ ខ្សែ** ប្រវែង **៩៨.៦០៧ ម** សាច់ដីសរុបចំនួន **២៦.៧២៤ ម៣** ។

### ១.៤.ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក

**ក-រៀបចំបង្កើតសហគមន៍កសិកប្រើប្រាស់ទឹក**

ក្រសួង និងមន្ទីរបានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្រ ក្នុងឆ្នាំ ២០១៩ ក្នុងខេត្តកំពង់ធំ តាកែវ ព្រះវិហារ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ចាម និងខេត្តសៀមរាប សម្រេចបានសរុបចំនួន **១៣ សហគមន៍** ដែលមានផ្ទៃដីស្រូវសរុប **៣៣.៣៥៨ ហ.ត** ក្នុងនោះផ្ទៃដីស្រូវវស្សា **២៨.៩៥៥ហ.ត** ស្រូវប្រាំង **៤.៤០៣ ហ.ត** និងមាន **២១.៣០៨ គ្រួសារ** ។

**ខ-ការងារចុះពង្រឹងសហគមន៍កសិកប្រើប្រាស់ទឹក ដែលបានបង្កើតរួច**

មន្ទីរធទឧតាមបណ្ដារាជធានី-ខេត្តបាន ធ្វើការចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្រ ក្នុងឆ្នាំ២០១៩ បានសរុបចំនួន ១២៧កន្លែង ក្នុងនោះខេត្តស្វាយរៀង ៧កន្លែង ខេត្តព្រៃវែង ១០កន្លែង ខេត្តត្បូងឃ្មុំ ៦កន្លែង ខេត្តកំពង់ចាម ៦កន្លែង ខេត្តកណ្ដាល ៤កន្លែង រាជធានីភ្នំពេញ ២កន្លែង ខេត្តតាកែវ ១៤កន្លែង ខេត្តកំពត ២កន្លែង ខេត្តកំពង់ស្ពឺ ៧កន្លែង ខេត្តកែប ៥កន្លែង ខេត្តព្រះសីហនុ ១កន្លែង ខេត្តកោះកុង ២កន្លែង ខេត្តកំពង់ឆ្នាំង ៤កន្លែង ខេត្តពោធិ៍សាត់ ៧កន្លែង ខេត្តបាត់ដំបង ១៥កន្លែង ខេត្តប៉ៃលិន ២កន្លែង ខេត្តបន្ទាយមានជ័យ ១កន្លែង ខេត្តឧត្តរមានជ័យ ៣កន្លែង ខេត្តកំពង់ធំ ៦កន្លែង ខេត្តព្រះវិហារ ២កន្លែង ខេត្តក្រចេះ ៩កន្លែង ខេត្តស្ទឹងត្រែង ៩កន្លែង ខេត្តរតនគិរី ៣កន្លែង ។

**២.ការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ( ក្នុងយុទ្ធសាស្ត្រទី២ / កម្មវិធីទី២ របស់ក្រសួង )**

ក្រសួងសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

**២.១.ការគ្រប់គ្រង និងការកាត់បន្ថយគ្រោះទឹកជំនន់-ទឹកប្រៃ**

**២.១.១.ទប់ស្កាត់ទឹកជំនន់៖**

**ក-ការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកជំនន់**

បានធ្វើការជួសជុលទំនប់ការពារទប់ស្កាត់ទឹកជំនន់ស្រុកពញាឮ ខេត្តកណ្ដាល **បានចំនួន ១ គម្រោង** ដែលមានលទ្ធភាពការពារផ្ទៃដីសរុបចំនួន **១០០ ហ.ត** ។

**ខ-ការជួសជុល-ថែទាំទំនប់ជាប្រចាំ ដើម្បីរក្សានិរន្តរភាពនៃការពារទប់ស្កាត់ទឹកជំនន់**

បានធ្វើការជួសជុល-ថែទាំទំនប់ការពារទប់ស្កាត់ទឹកជំនន់នៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល **បានចំនួន ២ គម្រោង** ដែលរក្សានិរន្តរភាពនៃលទ្ធភាពការពារផ្ទៃដីសរុប **៤.៩០១ហ.ត** ក្នុងនោះ (លំនៅដ្ឋានប្រជាពលរដ្ឋ បានចំនួន **២.៣២០ហ.ត** ការពារផ្ទៃដីស្រូវ **២.៥៨១ហ.ត**) ។

**គ-ការការពារច្រាំងទន្លេ ដើម្បីការពារទប់ស្កាត់ទឹកជំនន់**

ក្រសួងបានអនុវត្តន៍ការងាររៀបចំការពារច្រាំងទន្លេនៅខេត្តកណ្ដាល ខេត្តកំពង់ចាម និងខេត្តក្រចេះ បានចំនួន ៧ កន្លែង សម្រេចបានប្រវែង **១៣.៥៩៥ ម** ។

**២.១.២.ទប់ស្កាត់ទឹកប្រៃ៖**

**ក-ការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃ**

ក្រសួងបានធ្វើការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃបានចំនួន **០២ គម្រោង** នៅខេត្តកោះកុង ហើយការពារទប់ស្កាត់ទឹកប្រៃ កុំឲ្យប៉ះពាល់ផ្ទៃដី សរុបចំនួន **៦៧៥ ហ.ត** ក្នុងនោះ(ស្រូវវស្សា **៦២៥ ហ.ត** ស្រូវប្រាំង **៣០ ហ.ត** និងដំណាំ **២០ ហ.ត**)។

**ខ-ការជួសជុល-ថែទាំទំនប់ជាប្រចាំ ដើម្បីរក្សានិរន្តរភាពនៃការពារទប់ស្កាត់ទឹកប្រៃ**

បានធ្វើការជួសជុល និងថែទាំជាប្រចាំទំនប់ការពារទប់ស្កាត់ទឹកប្រៃបានចំនួន **១៦ គម្រោង** នៅខេត្តកោះកុង និងខេត្តព្រះសីហនុ ចំណាយថវិកាសរុបចំនួន **១.២៦៨.២៨០.០០០ រៀល** ហើយការពារទប់ស្កាត់ទឹកប្រៃ កុំឲ្យប៉ះពាល់ផ្ទៃដី សរុបចំនួន **១៥.៨៩៩ ហ.ត** ក្នុងនោះ (លំនៅដ្ឋានប្រជាពលរដ្ឋ **៣៨៦ ហ.ត** ស្រូវ **១៥.៤០៣ ហ.ត** ដំណាំ **១១០ ហ.ត**) ។

**២.២.ការគ្រប់គ្រង និងការអន្តរគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត**

គ្រោះគ្រោះរាំងស្ងួតតែងកើតមានឡើង ដោយការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលិតផលកសិកម្ម ដែលជាហេតុបណ្ដាលឲ្យទិន្នផលស្រូវធ្លាក់ចុះ ធ្វើឲ្យប្រជាកសិករមានចំណូលទាប ។ ក្នុងន័យនេះ ការអន្តរាគមន៍ដោយម៉ាស៊ីនបូមទឹកដែលជួយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើរតួយ៉ាងសំខាន់ក្នុងការសង្គ្រោះ បន្ធូរបន្ថយ និងកែលម្អដំណាំកសិកម្មដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត ។

**២.២.១.ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត**

ក្រសួងធនធានទឹក និងឧតុនិយម បានប្រមូលផ្ដុំនូវម៉ាស៊ីនបូមទឹក និងមធ្យោបាយចាំបាច់នានា ក្នុងការអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ ដែលប៉ះពាល់ពីគ្រោះរាំងស្ងួតក្នុងឆ្នាំ២០១៩ បានចំណាយប្រេងម៉ាស៊ូត សរុបចំនួន **១.១៥០.០០០ លីត្រ** និងប្រេងម៉ាស៊ីនសរុបចំនួន **៥.៦០០ លីត្រ** សង្គ្រោះស្រូវបានសរុបចំនួន **៩០.១៨៩ ហ.ត** ក្នុងនោះ (ស្រូវប្រាំង **៤៧.៨៩២ ហ.ត** ស្រូវវស្សា **៤២.២៩៧ ហ.ត**) ។

ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវ ដោយម៉ាស៊ីនបូមទឹក ក៏មានការងារសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ (បង្ហូរ) បានចំនួន **១.៤២១ ហ.ត** ក្នុងនោះស្រូវប្រាំង **៥៨២ ហ.ត** និងស្រូវវស្សា **៨៣៩ ហ.ត** ។

**២.២.២.ការដំឡើង-ជួសជុល ស្ថានីយបូមទឹក និងម៉ាស៊ីនបូមទឹក**

ដើម្បីឲ្យការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវបានសម្រេច ក្រសួងបានធ្វើការះ

-ជួសជុលស្ថានីយបូមទឹកចំនួន **០៣ កន្លែង** និងជួសជុលម៉ាស៊ីនបូមទឹកចល័តចំនួន **៤៩ គ្រឿង** ។

**៣.ការការពារ និងអភិរក្សធនធានទឹក សម្រាប់និរន្តរភាពនៃទឹក (ក្នុងយុទ្ធសាស្ត្រទី៣ / កម្មវិធីទី៣ របស់ក្រសួង) ៖**

ដើម្បីអនុវត្តន៍ច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានរៀបចំដោយស្ថាប័ននៃរាជរដ្ឋាភិបាល ហើយត្រូវបានព្រះករុណាឡាយព្រះហត្ថលេខា ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ បន្ទាប់ពីព្រឹទ្ធសភាប្រជុំអនុម័តនៅថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៧ និងរដ្ឋសភាប្រជុំអនុម័ត នៅថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នោះ ៖

-ក្រសួងបានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពី ការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅតាមរាជធានី-ខេត្ត និងតាមសហគមន៍កសិករប្រើប្រាស់ទឹក ។ ជាមួយនេះដែរ បានចុះកំណត់ផ្ទៃដីអាងទឹកនៅខេត្តឧត្តរមានជ័យ ១ កន្លែង រាជធានីភ្នំពេញ ៣ កន្លែង និងខេត្តកំពង់ស្ពឺ ៩ កន្លែង ។

-ក្រសួងបានធ្វើការតាមដាន និងវាស់កម្រិតនីវ៉ូស្តាទិចទឹកអណ្តូង នៅខេត្តព្រៃវែង ១៨ កន្លែង និងខេត្តកំពង់ស្ពឺ ៥ កន្លែង ។ ជាមួយនេះដែរ ក្រសួងបានជីកខួងអណ្តូងទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់ នៅខេត្តព្រៃវែង ២៩ អណ្តូង និងជីកស្រះយកទឹកប្រើប្រាស់នៅខេត្តកំពង់ធំ ១៦ ស្រះ ខេត្តពោធិ៍សាត់ ៨៦ ស្រះ និងខេត្តឧត្តរមានជ័យ ១ ស្រះ ។

**៤.ការគ្រប់គ្រងព័ត៌មាន ស្តីពីធនធានទឹក និងឧតុនិយម ( ក្នុងយុទ្ធសាស្ត្រទី៤ / កម្មវិធីទី៤ របស់ក្រសួង ) ៖**

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការប្រែប្រួលអាកាសធាតុបានបណ្តាលឲ្យកើតមានឡើងនូវគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលជាគ្រោះធម្មជាតិដ៏ធំ បានធ្វើឲ្យបាត់បង់ដល់អាយុជីវិតមនុស្ស សត្វ ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន ។ ដើម្បីទប់ទល់ និងកាត់បន្ថយនូវគ្រោះមហន្តរាយធម្មជាតិនេះ ទាមទារឲ្យមានការដំឡើងស្ថានីយឧតុនិយម និងស្ថានីយជលសាស្ត្រ នៅតាមទន្លេ ដងទន្លេ និងស្ទឹងសំខាន់ៗ ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់ និងកម្រិតកម្ពស់ទឹក ទិន្នន័យធារទឹក សម្រាប់ធ្វើការព្យាករណ៍ស្ថានភាពឧតុនិយម និងស្ថានភាពជលសាស្ត្រឲ្យបានទៀងទាត់ សុក្រឹត និងផ្សព្វផ្សាយជូនដំណឹងទាន់ពេលជូនដល់សាធារណជន ឲ្យបានមុនពេលគ្រោះមហន្តរាយពីធម្មជាតិកើតឡើង ដូចជាភាពរាំងស្ងួត ខ្យល់ព្យុះ រន្ទះ និងទឹកជំនន់ ។ សមិទ្ធផលការងារខាងលើក្រសួងសម្រេចបានដូចខាងក្រោម ៖

**៤.១.ការងារជលសាស្ត្រ**

-ជួសជុលស្ថានីយជលសាស្ត្រ **១ កន្លែង** ដំឡើងក្តារវាស់កម្ពស់ទឹកចំនួន ១ កន្លែង និងជួសជុលក្តារម៉ែត្រ ១ កន្លែង ។

**៤.២.ការងារឧតុនិយម**

-ជួសជុលកែលម្អស្ថានីយឧតុនិយមបានសរុបចំនួន **៦ កន្លែង** និងដំឡើងប៉ុស្តិ៍តម្រងទឹកភ្លៀងចំនួន **២០ កន្លែង** និងជួសជុលប៉ុស្តិ៍តម្រងទឹកភ្លៀងសរុបបានចំនួន **៥ កន្លែង** ។

-ក្រសួងបានធ្វើការជួសជុល-ថែទាំស្ថានីយឧតុនិយម (ស្ថានីយរ៉ាដាតេជោសែន) ។

**៥. ការគ្រប់គ្រងរដ្ឋបាល និងសេវាទូទៅ (ក្នុងយុទ្ធសាស្ត្រទី៥ / កម្មវិធីទី៥ របស់ក្រសួង) ៖**

ដើម្បីពង្រឹងស្ថាប័ន និងសមត្ថភាពចំណេះដឹងថ្មីៗដល់មន្ត្រីរាជការ ក្រសួងធនធានទឹក និងឧតុនិយម បញ្ជូនមន្ត្រីរាជការចូលរួមក្នុងសិក្ខាសាលា និងបានបណ្តុះបណ្តាលដល់មន្ត្រីគ្រប់លំដាប់ថ្នាក់នូវមុខវិជ្ជាពាក់ព័ន្ធដល់កិច្ចអភិវឌ្ឍវិស័យធនធានទឹក និងឧតុនិយមទាំងក្នុងប្រទេស និងក្រៅប្រទេស ដោយមានការយកចិត្តទុកដាក់ និងលើកទឹកចិត្តដល់មន្ត្រីជាស្ត្រីឲ្យចូលរួមផងដែរ។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ៥.១. បណ្តុះបណ្តាល | - ក្នុងប្រទេសបានចំនួន | ២៣៧ | នាក់ |
| | - ក្រៅប្រទេសបានចំនួន | ១៩ | នាក់ |
| | **សរុបចំនួន** | **២៥៦** | **នាក់** |
| ៥.២. សិក្ខាសាលា | - ក្នុងប្រទេសបានចំនួន | ២៩៦ | នាក់ |
| | - ក្រៅប្រទេសបានចំនួន | ៣២ | នាក់ |
| | **សរុបចំនួន** | **៣២៨** | **នាក់** |

ក្រៅពីនេះក្រសួងបានបើកវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា សរុបចំនួន **២៩ វគ្គ** ។

**ខ-អាជ្ញាធរទន្លេសាប ៖**

ផែនការសកម្មភាពប្រចាំឆ្នាំអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ២០១៩ ត្រូវបានអនុម័តនាដើមឆ្នាំ ២០១៩ ។ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំធ្វើការផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរួមសហការ និងអនុវត្តន៍ឲ្យមានប្រសិទ្ធភាព ។

ឆ្លងតាមការតាមដានត្រួតពិនិត្យ និងវាយតម្លៃពីវឌ្ឍនភាពការងារនៃការអនុវត្តរយៈពេល ១ ឆ្នាំ (២០១៩) បានបង្ហាញឲ្យឃើញថា សកម្មភាពការងារ ដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០១៩ សម្រេចបាន ៩៥ (ភាគរយ) និងមានសកម្មភាពការងារចំនួន ៥ (ភាគរយ) មិនទាន់បានអនុវត្តន៍ពេញលេញនៅឡើយ ។

❖ **ការការពារ និងអភិរក្សធនធានទឹក (ក្នុងយុទ្ធសាស្ត្រទី៣ / កម្មវិធីទី៣ របស់អាជ្ញាធរទន្លេសាប) ៖**

**ខ.១. ថ្នាក់អគ្គលេខាធិការដ្ឋានបានសម្រេច ៖**

- កំណត់រាល់សូចនាករជាធាតុចូលសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទន្លេសាប
- កំណត់ពីសូចនាករ និងទស្សនទានដែលជាធាតុចូលសំខាន់ៗនៃគោលការណ៍គ្រប់គ្រងធានធានទឹកចម្រុះសម្រាប់ការអភិវឌ្ឍ និងអភិរក្សតំបន់ទន្លេសាបប្រកបដោយចីរភាព
- សិក្សាស្រាវជ្រាវពីស្ថានភាព និងសក្តានុពលទេសចរណ៍ធម្មជាតិនៅតំបន់ទន្លេសាប
- សិក្សាស្រាវជ្រាវ និងលើកកម្ពស់ការយល់ដឹងពីការគ្រប់គ្រងកាកសំណល់បណ្តាលមកពីការចោលឧបករណ៍នេសាទជុំវិញតំបន់ទន្លេសាប
- ផ្សព្វផ្សាយលទ្ធផលបឋមនៃការសិក្សាស្រាវជ្រាវអំពីកាកសំណល់រឹងភូមិបណ្តែតទឹកនៃតំបន់ទន្លេសាប
- សម្របសម្រួលជាមួយក្រសួងស្ថាប័នជាតិ រៀបចំបង្កើត និងពង្រឹងនីតិវិធី/វិធីសាស្ត្រតាមដានត្រួតពិនិត្យ និងវាយតម្លៃ
- ចែករំលែកការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់ទន្លេសាប

- ចូលរួមផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកការយល់ដឹង ក្នុងកិច្ចដំណើរការការអភិវឌ្ឍប្រកបដោយចីរភាពក្នុងកិច្ចការពារធនធានធម្មជាតិ និងបរិស្ថាន
- ចងក្រងកម្រងរបាយការណ៍បច្ចេកទេសសិក្សាស្រាវជ្រាវ សេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងតំបន់ទន្លេសាប
- រៀបចំរបាយការណ៍បច្ចេកទេសស្តីពី ស្ថានភាពសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ និងការគ្រប់គ្រងបឹងទន្លេសាប
- រៀបចំយន្តការការងារ និងវិធីសាស្រ្តរៀបចំផែនការយុទ្ធសាស្រ្ត
- ប្រមូលចងក្រង និងវិភាគរាល់ឯកសារ និងស្ថានភាពពាក់ព័ន្ធ
- ពង្រឹងបណ្តាញទំនាក់ទំនងការងារ ជាមួយនឹងអង្គការអាងទន្លេ ថ្នាក់តំបន់ និងអន្តរជាតិ
- ទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរចំណេះដឹង និងចែករំលែកបទពិសោធន៍ ការគ្រប់គ្រងតំបន់ទន្លេសាប

**ខ.២. ថ្នាក់នាយកដ្ឋាន**

- **នាយកដ្ឋានធនធានធម្មជាតិ**

- បច្ចុប្បន្នភាពការកំណត់ដែនវិសាលភាពនៃតំបន់បឹងទន្លេសាប (ព្រះរាជក្រឹត្យ-មាត្រា ២)
- អធិការកិច្ចដែនព្រៃលិចទឹកដើម្បីសហការ និងការពារដែនព្រៃលិចទឹក (តំបន់៣)ព្រមទាំងពិនិត្យ និងថែទាំបង្គោលព្រំដែនព្រៃលិចទឹកតំបន់ ៣
- សកម្មភាពសិក្សាស្រាវជ្រាវពីព្រៃលិចទឹក តាមបណ្តាស្ទឹង និងការទាញយកអនុផលព្រៃលិចទឹកក្នុងតំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សម្របសម្រួល សហការដាំព្រៃលិចទឹកឡើងវិញ និងបង្កើតថ្នាលបណ្តុះកូនឈើព្រៃលិចទឹកក្នុងតំបន់ទន្លេសាប
- សិក្សាស្រាវជ្រាវពីបម្រែបម្រួលរបបជលសាស្រ្ត និងលក្ខណៈជីវសាស្រ្តនៃការបន្លាស់ទីធនធានជីវចម្រុះនៅតំបន់ទីជម្រាលបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីការបន្លាស់ទីធនធានជលផលនៅតំបន់បឹងទន្លេសាប ទន្លេមេគង្គ ទន្លេបាសាក់ និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីការប្រើប្រាស់ធនធានជលផលនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធសម្រាប់វិស័យវារីវប្បកម្ម
- សិក្សាស្រាវជ្រាវ និងវាយតម្លៃលើការប៉ះពាល់នៃគុណភាពទឹកតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីផលប៉ះពាល់គុណភាពទឹក នៅតាមបណ្តាដងស្ទឹងសំខាន់ៗ តំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវពីការប្រមូល និងការគ្រប់គ្រងទឹកភ្លៀងនៅតាមជនបទ និងទីប្រជុំជនខេត្តកំពង់ឆ្នាំង
- សិក្សាពីផលប៉ះពាល់លើធនធានរ៉ែនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ
- ចុះសិក្សាពីបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌតំបន់ដីសើម តំបន់ការពារធនធានធម្មជាតិ (Ramsar) និងការប្រើប្រាស់ផ្ទៃដីកសិកម្មតំបន់ទន្លេសាបក្រោមផ្លូវជាតិលេខ ៥ និង ៦ជុំវិញតំបន់ទន្លេសាប

- **នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស**
  - សិក្សាការផ្លាស់ប្តូរគម្របដី (Land Cover Change) តំបន់វាលទំនាបលិចទឹកជុំវិញបឹងទន្លេសាប
  - ការធ្វើបច្ចុប្បន្នភាពផែនទី Atlas នៅខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
  - សិក្សាពីការធ្វើអាជីវកម្មសិប្បីសត្វ (លៀស ខ្ចៅ ខ្យង) នៅខេត្តសៀមរាប
  - សិក្សាតាមដានបរិមាណផលចាប់តាមឧបករណ៍ឡូត៍ដាយត្រី រាជធានីភ្នំពេញ និងខេត្តកណ្តាល
  - តាមដានផលនេសាទរបស់អ្នកនេសាទនៅតាមដងស្ទឹងទាំង ១០ ជុំវិញបឹងទន្លេសាប
  - សិក្សាពីខ្សែសង្វាក់នៃការធ្វើអាជីវកម្មប្រហុកនៅខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប
  - សិក្សាស្ថានភាពភូមិសាស្ត្រទូទៅអន្លង់នៃតំបន់អភិរក្សជលផល
- **នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ**
  - ផ្សព្វផ្សាយ និងបង្កើនការយល់ដឹងគោលនយោបាយគ្រប់គ្រងធនធានទឹកឲ្យបានទូលំទូលាយដល់មន្ត្រីអាជ្ញាធរទន្លេសាប
  - សិក្សាស្រាវជ្រាវប្រសិទ្ធភាពផលប៉ះពាល់លើការងារអនុវត្តន៍ច្បាប់និងបទបញ្ញត្តិនានាពាក់ព័ន្ធការគ្រប់គ្រងអភិវឌ្ឍន៍ និងអភិរក្សបរិស្ថាន ធនធានធម្មជាតិនៅតំបន់ទន្លេសាប ប្រកបដោយតុល្យភាព
  - សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញដើម្បីប្រមូល និងចងក្រងបទដ្ឋានគតិយុត្ត/ច្បាប់នានា ពាក់ព័ន្ធក្នុងកិច្ចការងារគ្រប់គ្រង និងអភិវឌ្ឍធនធានធម្មជាតិ
  - សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញ និងដៃគូអភិវឌ្ឍន៍ធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពីបទបញ្ញត្តិពាក់ព័ន្ធ នឹងការគ្រប់គ្រងបរិស្ថាន ធនធានធម្មជាតិ ដល់មន្ត្រី អទស និងសហគមន៍មូលដ្ឋាន
  - សិក្សាស្រាវជ្រាវពីប្រវត្តិស្ថានភាពទូទៅនៃបឹងទន្លេសាបក្នុងបរិបទប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងបរិស្ថានធនធានធម្មជាតិ (ឆ្នាំ ២០១៨-២០២០)
  - សិក្សាស្រាវជ្រាវពីការគ្រប់គ្រង និងការដោះស្រាយវិវាទផលប្រយោជន៍ក្នុងការប្រើប្រាស់ ធនធានធម្មជាតិប្រកបដោយសមធម៌ និងចីរភាព
  - សិក្សាពីស្ថានភាពទូទៅនៃផ្នែកសេដ្ឋកិច្ចសង្គម និងការប្រើប្រាស់ធនធានធម្មជាតិ នៅតំបន់ស្នួល (ព្រែកទាល់) ខេត្តបាត់ដំបង
  - សិក្សាបច្ចុប្បន្នភាពប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម នៅតាមបណ្តាស្ទឹងជុំវិញបឹងទន្លេសាប
  - ពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយក្រសួងស្ថាប័ន ក្នុងការតាមដានផលប៉ះពាល់ទៅលើធនធានធម្មជាតិ បរិស្ថាន និងលក្ខខ័ណ្ឌសេដ្ឋកិច្ច សង្គមកិច្ច
  - ជម្រុញ និងបង្កើនការផ្សព្វផ្សាយ ព័ត៌មាន/ទិន្នន័យតាមប្រព័ន្ធ អេឡិចត្រូនិក (គេហទំព័របណ្តាញសង្គម...) និងការបោះពុម្ពផ្សាយ
  - ចងក្រងរាល់ឯកសារបច្ចេកទេស បទដ្ឋានគតិយុត្ត/ច្បាប់ គោលនយោបាយ និងបទបញ្ញត្តិពាក់ព័ន្ធនឹងដំណើរការការងារនៃការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងអាងទន្លេ
  - ពង្រឹងសមត្ថភាពពីការគ្រប់គ្រងព័ត៌មានវិទ្យា (Information Technology Management) ។

❖ **ការគ្រប់គ្រងរដ្ឋបាល និងសេវាទូទៅ (ក្នុងយុទ្ធសាស្ត្រទី៥ / កម្មវិធីទី៥ របស់អាជ្ញាធរទន្លេសាប)៖**

**ខ.១. ថ្នាក់នាយកដ្ឋាន**

- **នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ**

- រៀបចំប្រជុំផ្ទៃក្នុងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ពីដំណើរការ និងការប្រព្រឹត្តិទៅរបស់អាជ្ញាធរទន្លេសាប
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីវឌ្ឍនភាពការងារប្រចាំឆ្នាំ និងទិសដៅបន្តរបស់អាជ្ញាធរទន្លេសាប
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំនីតិវិធី/វិធីសាស្ត្រ និងចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោងនីមួយៗដែលបាន និងកំពុងអនុវត្តនៅក្នុងតំបន់ទន្លេសាប
- បច្ចុប្បន្នភាពទិន្នន័យគម្រោង ថ្នាក់ក្រោមជាតិ ដែលបាននឹងកំពុងអនុវត្តន៍ក្នុងតំបន់ទន្លេសាប
- វគ្គពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស អំពីវិធីសាស្ត្រ និងនីតិវិធីនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃរបស់កម្មវិធី/គម្រោង
- បង្កើនការលើកទឹកចិត្ត និងពង្រឹងការយល់ដឹង ដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ
- តាមដានត្រួតពិនិត្យ និងវាយតម្លៃ វឌ្ឍនភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៦-២០២០
- រៀបចំផែនការសកម្មភាព ២០២០ របស់អាជ្ញាធរទន្លេសាប
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ផែនការសកម្មភាព ២០១៩
- រៀបចំគម្រោងវិនិយោគសាធារណៈ PIP ២០១៩-២០២១ សម្រាប់អាជ្ញាធរទន្លេសាប
- ពង្រឹងប្រសិទ្ធភាពការកសាងផែនការ ថវិកាកម្មវិធីប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប
- សមាហរណកម្មប្រភពថវិកា/មូលនិធិ (ថវិការដ្ឋ ម្ចាស់ជំនួយ គម្រោងនានា...) ក្នុងផែនការថវិការបស់អាជ្ញាធរទន្លេសាប
- ផ្គត់ផ្គង់សម្ភារបរិក្ខា ប្រេងឥន្ធនៈ និងមធ្យោបាយសម្រាប់ប្រតិបត្តិការការងាររបស់អាជ្ញាធរទន្លេសាប
- ជួសជុលថែទាំ មធ្យោបាយ សម្ភារបរិក្ខា និងអគារសម្រាប់អាជ្ញាធរទន្លេសាប
- ពង្រឹងប្រសិទ្ធភាពការងារគ្រប់គ្រងរដ្ឋបាល បុគ្គលិក មន្ត្រីរាជការក្នុងដំណើរការការងារប្រចាំថ្ងៃរបស់អាជ្ញាធរទន្លេសាប
- បង្កើនការយកចិត្តទុកដាក់ និងលើកទឹកចិត្តជូនមន្ត្រីរាជការបម្រើការងារនៅ អាជ្ញាធរទន្លេសាប
- ជ្រើសរើស និងបញ្ចូលមន្ត្រីជាប់សន្យា ។

**គ-គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ៖**

**គ.១- កម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា គឺជាស្ថាប័នសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់តំបន់មានសមត្ថភាពបច្ចេកទេស ចូលរួមក្នុងការសម្របសម្រួលការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ ដែលបានរួមចំណែកទៅនឹងទិសដៅជាយុទ្ធសាស្ត្រនៃកម្មវិធីគ្រប់គ្រង និងអភិវឌ្ឍធនធានទឹក របស់ក្រសួងធនធានទឹក និងឧតុនិយម នៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្នាំ២០១៩ ជាឆ្នាំទី៤ នៃការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គ.ជ.ទ.ម.ក) ជាមួយនឹងការអនុវត្តផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ ដំណាលគ្នា ឆ្នាំ ២០១៦-២០២០ របស់

គណៈកម្មការទន្លេមេគង្គ (គ.ទ.ម) ផងដែរ ហើយក៏ជាឆ្នាំទី១ នៃការចូលរួមអនុវត្តគោលនយោបាយ និងផែនការជាអាទិភាពរបស់រាជរដ្ឋាភិបាលដូចមានចែងក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៥ឆ្នាំ ២០១៩-២០២៣ ។ ក្នុងរយៈពេលជាង ២ ទសវត្សកន្លងទៅនេះ កម្ពុជាក្នុងនាមជាប្រទេសសមាជិក គ.ទ.ម រួមជាមួយប្រទេសជាសមាជិក ឡាវ ថៃ និងវៀតណាម បានធ្វើការសហការគ្នាក្នុងតំបន់ និងសម្រេចបាននូវសមិទ្ធផល ជាច្រើនគួរឲ្យកត់សម្គាល់រួមមាន ការកសាងផែនការអាងទន្លេ ការព្យាករណ៍ទឹកជំនន់ ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ការត្រួតពិនិត្យតាមដាននិងវាយតម្លៃ និងគ្រប់គ្រងជលផល នាវាចរណ៍ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃគុណភាពទឹក ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាព ។ សមិទ្ធផល ជោគជ័យសំខាន់ដទៃទៀតដែលមានលក្ខណៈជាប្រវត្តិសាស្ត្រនោះគឺ ការបង្កើតឡើង និងការអនុវត្តនីតិវិធីប្រើប្រាស់ទឹកទាំង៥ ប្រើជាឧបករណ៍អភិបាលកិច្ចសម្រាប់គ្រប់គ្រង ការប្រើប្រាស់ទឹកប្រកបដោយសមភាព និងសមធម៌ ក្នុងគោលដៅធានាឲ្យបាននូវការអភិវឌ្ឍ និងការគ្រប់គ្រងទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គប្រកបដោយចីរភាព និងការបន្តអនុវត្តនូវផែនការវិមជ្ឈការមុខងារស្នូលរបស់ គ.ទ.ម ។

លទ្ធផលការងារសម្រេចបានរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ឆ្លើយតបក្នុងទិសដៅជាយុទ្ធសាស្ត្រទី១ **នៃកម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក** មានដូចខាងក្រោមគឺ ៖

✓ **វឌ្ឍនភាព និងសមិទ្ធផលកម្រិតគោលនយោបាយ និងអភិបាលកិច្ច ៖**

- **រៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប្រចាំឆ្នាំ ២០១៩**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានរៀបចំកិច្ចប្រជុំលើកទី១ ប្រចាំឆ្នាំ ២០១៩ ក្រោមអធិបតីភាព **ឯកឧត្តម លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធាន គ.ជ.ទ.ម.ក និងមានការអញ្ជើញចូលរួមដោយ ឯកឧត្តម លោកជំទាវ ជាអនុប្រធាន អនុប្រធានអចិន្ត្រៃយ៍ សមាជិក សមាជិកា គ.ជ.ទ.ម.ក និងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក សរុបចំនួន ៥៥ នាក់ ដែលបានប្រព្រឹត្តទៅនា ថ្ងៃ ទី១៣ ខែ សីហា ឆ្នាំ ២០១៩ ។ ក្នុងប្រសាសន៍ថ្លែង ស្វាគមន៍ និងបើកអង្គប្រជុំ ឯកឧត្តមប្រធាន បានសំដែងនូវការអបអរសាទរចំពោះ ឯកឧត្តម លោកជំទាវ ជារដ្ឋលេខាធិការ អគ្គលេខាធិការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលត្រូវបានតែងតាំងជាអនុប្រធាន អនុប្រធានអចិន្ត្រៃយ៍ សមាជិក សមាជិកាគ.ជ.ទ.ម.ក តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៦១៩/៩២១ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៩ ស្តីពីការតែងតាំងសមាសភាពគ.ជ.ទ.ម.ក ។ ឯកឧត្តមប្រធាន បានធ្វើការកត់សម្គាល់លើកត្តាសំខាន់ៗ ដែលជាភាពប្រឈមក្នុងការអនុវត្តការងាររបស់ គ.ជ.ទ.ម.ក ដែលបំពេញកិច្ចការក្នុងក្របខណ្ឌប្រទេសផង និងក្នុងក្របខណ្ឌគ.ទ.មផង ដែលទាំងអស់នេះបានបង្ហាញពីការប្តេជ្ញាចិត្ត និងកិច្ចខិតខំសហការរួមគ្នារវាងក្រសួង-ស្ថាប័នជាសមាជិក គ.ជ.ទ.ម.ក និងប្រទេសជាសមាជិក គ.ទ.ម ព្រមទាំងប្រទេសដៃគូសន្ទាន (ចិន និងមីយ៉ាន់ម៉ា) ។ ឯកឧត្តមប្រធាន បានវាយតម្លៃខ្ពស់អំពីសមិទ្ធផលសម្រេចបានរបស់ គ.ទ.ម ដែលមិនអាចខ្វះបានពីការចូលរួមរបស់ប្រទេសជាសមាជិក ជាពិសេសពីការសម្របសម្រួលការងាររបស់គ.ជ.ទ.ម.ក ។

- **កម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចកិច្ចសន្ទនាអាស៊ី-អឺរ៉ុបលើកទី ៨ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព**

ព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសបានធ្វើជាម្ចាស់ផ្ទះ នៃកិច្ចសន្ទនាអាស៊ី-អឺរ៉ុបលើកទី ៨ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពលើប្រធានបទ " ការលើកកម្ពស់ភាពជាដៃគូទឹកឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព និងភាពរីកចម្រើនសម្រាប់ទាំងអស់គ្នា " នាថ្ងៃទី១៩-២០ ខែកញ្ញា ឆ្នាំ២០១៩ នៅទីក្រុងសៀមរាប ដោយមានការចូលរួមពីតំណាងនៃអ្នកពាក់ព័ន្ធសំខាន់ៗមកពីអាស៊ីនិងអឺរ៉ុប ដូចជាមន្ត្រីរដ្ឋាភិបាល អ្នកជំនាញ

អ្នកស្រាវជ្រាវ និងតំណាងអង្គការក្រៅរដ្ឋាភិបាល ថ្នាក់ជាតិ តំបន់ និងអន្តរជាតិ សរុបចំនួន ១២០ រូប ។ កិច្ចសន្ទនាដែលមានរយៈពេលពីរថ្ងៃនេះ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយរាជរដ្ឋាភិបាលកម្ពុជា និងរៀបចំដោយ គ.ជ.ទ.ម.ក ដោយមានកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធសំខាន់ៗមួយចំនួន ។ ពិធីបើកនៃកិច្ចសន្ទនា បានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងមានការចូលរួមជាកិត្តិយស ដោយរដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធមួយចំនួនទីប្រឹក្សារាជរដ្ឋាភិបាល តំណាងនៃស្ថានទូតហុងគ្រី ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា សហគមន៍អឺរ៉ុប នាយកប្រតិបត្តិលេខាធិការដ្ឋាន គ.ទ.ម និងតំណាងអង្គការអាងទន្លេដានូប ។ កិច្ចសន្ទនាខាងលើបានសម្រេចនូវលទ្ធផលដោយបានប្តេជ្ញាពង្រឹងអភិបាលកិច្ច ដើម្បីដោះស្រាយបញ្ហាប្រឈមទឹកក្នុងតំបន់ និងពិភពលោកតាមរយៈការបង្កើនច្បាប់ និងស្ថាប័នដែលមានមូលដ្ឋានលើសន្ធិសញ្ញា និងយន្តការកិច្ចសហប្រតិបត្តិការដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការទឹក និងបង្កើនភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការបង្ការវិបត្តិទឹក នាពេលអនាគត និងបានបង្កើនភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការទឹក (ភាពជាដៃគូអាស៊ី-អឺរ៉ុបនិងសហប្រតិបត្តិការទឹកជាមួយយន្តការសំខាន់ៗ ដូចជា MRC, ASEM, Lancang Mekong Cooperation, ACMECs, មហាអនុតំបន់មេគង្គនិងគំនិតផ្តួចផ្តើមមេគង្គក្រោមបានបង្ហាញនូវការប្តេជ្ញាចិត្ត ដើម្បីលើកកម្ពស់ក្របខណ្ឌស្ថាប័ន ដែលមានមូលដ្ឋានលើវិធានច្បាប់ និងការបង្កើតគោលនយោបាយរួមគ្នានៅតំបន់ឆ្លងដែន ។ គ.ទ.ម ដែលជាអង្គការអាងទន្លេក្នុងតំបន់ បង្កើតឡើងដោយកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ បានលើកកម្ពស់កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ច ទន្ទឹមនឹងការអភិរក្សបរិស្ថាន និងអេកូឡូស៊ីនៃអាងទន្លេមេគង្គ និងការដោះស្រាយភាពខុសគ្នា ក្នុងចំណោមប្រទេសជាសមាជិក ផ្អែកលើកិច្ចព្រមព្រៀង និងព្រមទាំងបានស្នើឲ្យគណៈកម្មការទន្លេមេគង្គគិតគូរថ្លឹងថ្លែងអំពីតម្រូវការដែលមានភាពប្រទាក់ក្រឡាគ្នារវាងសន្តិសុខទឹក ស្បៀង ថាមពល និងនិរន្តរភាពបរិស្ថានដោយត្រូវមានការឆ្លុះបញ្ចាំងនៅក្នុងការងាររបស់ខ្លួន ដូចជា ក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ នាពេលបច្ចុប្បន្ន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេសម្រាប់ឆ្នាំ ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២១-២០២៥ ។

- **កិច្ចប្រជុំក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ MRC**

ក្នុងឆ្នាំ ២០១៩ ក្រុមប្រឹក្សា គ.ទ.ម បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួនលើកទី២៦ និងកិច្ចប្រជុំរួមលើកទី ២៤ ជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌគ.ទ.ម នៅរាជធានីភ្នំពេញ នាថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដឹកនាំប្រជុំដោយ **ឯកឧត្តម លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន គ.ជ.ទ.ម.ក និងជាប្រធានក្រុមប្រឹក្សា គ.ទ.ម ប្រចាំឆ្នាំ ២០១៩ និងមានការចូលរួមដោយសមាជិកក្រុមប្រឹក្សាថ្នាក់រដ្ឋមន្ត្រីពីប្រទេសជាសមាជិក គ.ទ.ម រួមមាន កម្ពុជា ឡាវ ថៃ និងវៀតណាម និងតំណាងនៃប្រទេសដៃគូអភិវឌ្ឍន៍ ដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) តំណាងស្ថាប័នហិរញ្ញវត្ថុ តំណាងអង្គការតំបន់និងអន្តរជាតិ សរុបចំនួន ១០០នាក់ ។ លទ្ធផលនៃកិច្ចប្រជុំ (i) បានអនុម័តផែនការការងារ គ.ទ.ម សម្រាប់ឆ្នាំ ២០២០-២០២១ និងឯកសារយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួតរបស់ គ.ទ.ម សម្រាប់ឆ្នាំ ២០២០-២០២៥ និងបានស្នើឲ្យលេខាធិ-ការដ្ឋាន គ.ទ.ម អនុវត្តផែនការការងារយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត ឲ្យមានប្រសិទ្ធភាព (ii) បានកត់ត្រា និងវាយតម្លៃខ្ពស់ ចំពោះសមិទ្ធផល និងវឌ្ឍនភាពនៃការអនុផែនការយុទ្ធសាស្ត្រ គ.ទ.ម ឆ្នាំ ២០១៦-២០២០ និងកិច្ចខំប្រឹងប្រែងរួមគ្នា កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ មានលក្ខណៈល្អប្រសើរក្នុងចំណោមប្រទេសជាសមាជិក និងរវាង គ.ទ.ម ជាមួយប្រទេសជាដៃគូសន្ទនា ដៃគូអភិវឌ្ឍន៍ អង្គការតំបន់ និងអន្តរជាតិ ។ សមិទ្ធផល និងវឌ្ឍនភាពការងារសម្រេចបាននេះ បានបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ (iii) បានថ្លែងអគុណចំពោះដៃគូអភិវឌ្ឍន៍ ដៃគូសន្ទនា និងដៃគូ

សហប្រតិបត្តិការពាក់ព័ន្ធផ្សេងទៀតដែលបានគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស និងបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ក្នុងកិច្ចប្រឹងប្រែងរួមគ្នា ជួយឲ្យ គ.ទ.ម សម្រេចបាននូវសមិទ្ធផលការងាររហូតដល់ពេលនេះ ជាពិសេសពាក់ព័ន្ធនឹងការអនុវត្តសេចក្តីថ្លែងការណ៍ក្រុងសៀមរាប នៃកិច្ចប្រជុំកំពូល គ.ទ.ម លើកទី៣ ក្នុងខែ មេសា ឆ្នាំ ២០១៨ នៅទីក្រុងសៀមរាប និង (iv) ដៃគូអភិវឌ្ឍន៍ បានអបអរសាទរចំពោះសមិទ្ធផលក្នុងក្របខណ្ឌ គ.ទ.ម ដែលសម្រេចបាន និងបានស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ជាដៃគូសន្ទនា និងយន្តការតំបន់ និងអន្តរជាតិផ្សេងទៀត និងបានបង្ហាញនូវការប្តេជ្ញាចិត្តបន្តជួយដល់ គ.ទ.ម ក្នុងការអនុអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍អាងទន្លេមេគង្គឆ្នាំ ២០២១-២០៣០ និងផែនការយុទ្ធសាស្រ្ត ឆ្នាំ២០២១-២០២៥ របស់ គ.ទ.ម ដែលបច្ចុប្បន្នបាន និងកំពុងរៀបចំដើម្បីបន្តឲ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ ។

- **កិច្ចប្រជុំគណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ**

ក្នុងឆ្នាំ ២០១៩ គណៈកម្មាធិការរួម នៃគណៈកម្មការទន្លេមេគង្គ បានរៀបចំកិច្ចប្រជុំ ចំនួន ២ លើក រួមមាន៖

**(១) កិច្ចប្រជុំលើកទី៤៨ របស់គណៈកម្មាធិការរួម គ.ទ.ម បានរៀបចំធ្វើនាថ្ងៃទី ២៤-២៥ ខែ មេសា ឆ្នាំ ២០១៩** នៅទីក្រុងវង់តាវ ប្រទេសវៀតណាម ដោយមានការចូលរួមពីប្រតិភូថ្នាក់គណៈកម្មាធិការរួម នៃប្រទេសជាសមាជិក MRC (កម្ពុជា ឡាវ ថៃ និងវៀតណាម) និងមន្រ្តីលេខាធិការដ្ឋាន គ.ទ.ម សរុបចំនួន ៥២រូប ។ ប្រតិភូកម្ពុជា ដឹកនាំដោយ **ឯកឧត្តម តែ ណាវុធ** អនុប្រធានអចិន្រ្តៃយ៍ គ.ជ.ទ.ម.ក និងជាសមាជិកគណៈកម្មាធិការរួម គ.ទ.ម តំណាងកម្ពុជា និងមានមន្ត្រីតំណាងចូលរួម មកពីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ លទ្ធផលនៃកិច្ចប្រជុំ រួមមាន (i) បានអនុម័តឯកសារបច្ចុប្បន្នភាពសៀវភៅក្បួនស្តីពី ទី១៖ ធនធានមនុស្ស ទី២៖ រដ្ឋបាល និងទី៣៖ លទ្ធកម្ម (ii) បានអនុម័តលើអនុសាសន៍លើការពិនិត្យឡើងវិញស្តីពីកិច្ចសហប្រតិបត្តិការ និងការអនុវត្តពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្រ្តគ.ទ.ម ឆ្នាំ២០១៦-២០២០ (iii) បានឯកភាពលើរបាយការណ៍ស្ថានភាពអាងទន្លេ ឆ្នាំ ២០១៨ សម្រាប់បោះពុម្ពនិងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនៅថ្នាក់ជាតិ និង (iv) បានឯកភាពលើក្របខណ្ឌសូចនាករ គ.ទ.ម (MRC Indicator Framework) ។

**(២) កិច្ចប្រជុំគណៈកម្មាធិការរួមលើកទី ៤៩ និងកិច្ចប្រជុំដៃគូសន្ទនា លើកទី ២៣** នៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី ៤-៥ ខែ កញ្ញា ឆ្នាំ ២០១៩ ។ ប្រតិភូកម្ពុជា ដែលបានចូលរួម មានចំនួន ០៧ ដឹកនាំដោយ ឯកឧត្តម **តែ ណាវុធ** អនុប្រធានអចិន្រ្តៃយ៍ គ.ជ.ទ.ម.ក និងមានសមាសភាពចូលរួមជាមន្រ្តីតំណាង មកពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន ក្រសួងរ៉ែ និងថាមពល និងអគ្គលេខាធិការដ្ឋានគ.ជ.ទ.ម.ក ។ លទ្ធផលកិច្ចប្រជុំបានពិនិត្យឡើងវិញលើវឌ្ឍនភាពការងារដែលលេខាធិការដ្ឋាន គ.ទ.ម សម្រេចបានផ្អែកលើផែនការការងារដែលបានដាក់ចេញ និងបានស្នើឲ្យលេខាធិការដ្ឋាន ត្រូវសហការជាមួយប្រទេសជាសមាជិក និងដៃគូពាក់ព័ន្ធផ្សេងទៀត ដើម្បីជម្រុញអនុវត្តឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យតាមផែនការគ្រោងទុក ។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាង គ.ទ.ម និងដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការវិវត្តរីកចម្រើនក្នុងកិច្ចសហប្រតិបត្តិការ ដែលបានសម្រេចបានមកដល់ពេលនេះនិងបានបង្ហាញនូវការប្តេជ្ញាចិត្ត ដើម្បីបន្តពង្រឹងឲ្យកាន់តែប្រសើរថែមទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នាសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ ។

✓ **ទន្លេនាព និងសមិទ្ធផលកម្រិតយន្តការសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ជាតិ**

ក្នុងឆ្នាំ ២០១៩ នេះ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានបន្តរក្សា និងពង្រីកភាពជាដៃគូជាមួយ **អង្គការក្នុងតំបន់ អង្គការអន្តរជាតិ និងជាមួយអង្គការអាងទន្លេនានា** តាមរយៈយន្តការផ្សេងៗ រួមមាន រៀបចំសិក្ខាសាលា វេទិកាបច្ចេកទេស ការទទួលយកអ្នកជំនាញការ ការផ្លាស់ប្តូរមន្ត្រីជំនាញ និងការផ្លាស់ប្តូរទស្សនកិច្ចសិក្សា ៖

- **យន្តការកិច្ចសហប្រត្តិការ មេគង្គ-ឡានឆាង** ( Mekong - Lancang Cooperation - MLC )

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចូលរួមសហការយ៉ាងល្អប្រសើរក្នុងយន្តការមេគង្គ-ឡានឆាង នេះ ក្រោយពីយន្តការនេះត្រូវបានបង្កើតឡើងក្នុងខែ មីនា ឆ្នាំ ២០១៦ ដោយបានចាត់តំណាងចូលរួមក្នុងក្រុមការងារលើវិស័យធនធានទឹក ។ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចាត់មន្ត្រីជាន់ខ្ពស់ មន្ត្រីថ្នាក់កណ្តាល និងមន្ត្រីបច្ចេកទេស ចូលរួមក្នុងកិច្ចប្រជុំការងារ ទស្សនកិច្ចសិក្សា វេទិកាវិស័យទឹក និងវគ្គបណ្តុះ-បណ្តាលបច្ចេកទេសនានា ដែលទ្រទ្រង់ដោយភាគីចិន ។ មជ្ឈមណ្ឌល សហប្រតិបត្តិការមេគង្គ-ឡានឆាង បានរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី១ នៃកិច្ចសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង នាថ្ងៃទី ១៧-១៨ ខែ ធ្នូ ឆ្នាំ ២០១៩ នៅទីក្រុងប៉េកាំង ប្រទេសចិន ដោយមានការអញ្ជើញចូលរួមពីគណៈប្រតិភូថ្នាក់រដ្ឋមន្ត្រីនៃប្រទេសទាំង ០៦ ។ គណៈប្រតិភូកម្ពុជា ដែលបានអញ្ជើញចូលរួម មានចំនួន ០៤រូប ដឹកនាំដោយ **ឯកឧត្តម ម៉ុន ហាន** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម និងមាន **ឯកឧត្តម វ៉ាត់ បុត្តកុសល** អគ្គលេខាធិការរង គ.ជ.ទ.ម.ក ។

- **យន្តការមេគង្គ-ជប៉ុន** ( Mekong – Japan )

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងនៃគំនិតផ្តួចផ្តើមមេគង្គ-ជប៉ុន សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្ពោះទៅកាន់ឆ្នាំ ២០៣០ (Mekong-Japan Initiative for SDGs toward សម្រាប់ការរៀបចំកិច្ចប្រជុំកំពូលមេគង្គ-ជប៉ុន លើកទី ១១ ។

- **យន្តការមេគង្គ-កូរ៉េ** ( Mekong – ROK )

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចូលរួមពិនិត្យ និងផ្តល់យោបល់លើឯកសារទស្សនទាន សម្រាប់ការរៀបចំកិច្ចប្រជុំកំពូល នៃកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ ដែលជាយន្តការកម្រិតខ្ពស់នៃប្រមុខរដ្ឋាភិបាលនៃបណ្តាប្រទេសមេគង្គ ជាមួយសាធារណរដ្ឋកូរ៉េ ដោយបានផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រៅពីនេះ ក៏បានសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ទទួលអនុវត្តគម្រោងគ្រប់គ្រងទឹកក្នុងអាងទន្លេមេគង្គ តភ្ជាប់ជាមួយអាងទន្លេសាប ដែលទ្រទ្រង់ថវិកាដោយសាធារណរដ្ឋកូរ៉េ ។

- **យន្តការគំនិតផ្តួចផ្តើមមេគង្គក្រោម** (Lower Mekong Initiative-LMI)

ក្រោមយន្តការ LMI របស់សហរដ្ឋអាមេរិក សម្រាប់ឆ្នាំ ២០១៩ គ.ជ.ទ.ម.ក បានចាត់មន្ត្រីរបស់ខ្លួនចូលរួមក្នុងព្រឹត្តិការណ៍ដូចជា ៖ កិច្ចប្រជុំជំនាញការទិន្នន័យទឹកមេគង្គ របស់ LMI នាថ្ងៃទី ៣-៤ ខែ មេសា ឆ្នាំ ២០១៩ នៅសហរដ្ឋអាមេរិក ដោយសម្រេចបាន៖ (១) ការឯកភាពលើប្រព័ន្ធទិន្នន័យមេគង្គជាមួយនឹងអ្នកពាក់ព័ន្ធ ដំណោះស្រាយលើបញ្ហាប្រឈម និងការរៀបគ្រោងប្លង់ដើម្បីទទួលបានទិន្នន័យ ការលើកកម្ពស់ការទទួលបានទិន្នន័យ និងទម្រង់ចែកចាយទិន្នន័យ (Data access and sharing Platform) (២) LMI សហការជាមួយ គ.ទ.ម ដើម្បីធ្វើឲ្យប្រសើរឡើងនូវការទទួលបានទិន្នន័យ និងទម្រង់ចែកចាយទិន្នន័យ តាមរយៈការងាររបស់ គ.ទ.ម ដោយដាក់ក្នុងរបៀបវារៈសំខាន់ៗ នូវការងារធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធទិន្នន័យ/ព័ត៌មាន និងកែទម្រង់រចនាសម្ព័ន្ធរបស់ គ.ទ.ម ។

សន្និសីទសិក្សាស្រាវជ្រាវពីមេគង្គ ឆ្នាំ២០១៩ នាថ្ងៃទី ១៦-១៨ ខែ ធ្នូ ឆ្នាំ ២០១៩ នៅប្រទេសវៀតណាម ដោយបានពិគ្រោះ និងប្រមូលមតិយោបល់ពីអ្នកចូលរួមពាក់ព័ន្ធនឹងស្ថានភាពទន្លេមេគង្គនាពេលបច្ចុប្បន្ន ការចែកចាយទិន្នន័យព័ត៌មានពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍តាមដងទន្លេមេគង្គ ផលប៉ះពាល់លើវិស័យពាក់ព័ន្ធនិរន្តរភាពទន្លេមេគង្គ និងការប្រើប្រាស់ឧបករណ៍វិភាគ វាយតម្លៃផលប៉ះពាល់ និងការបង្កើតសេណារីយ៉ូនៃការអភិវឌ្ឍដោយបញ្ចូលការអភិវឌ្ឍក្នុងតំបន់មេគង្គ និងការប្រែប្រួលអាកាសធាតុ និងបានពិគ្រោះលើការកំណត់អាទិភាពចម្រុះសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្ត ការប្រមូលទិន្នន័យជាធាតុចូលសម្រាប់ដាក់ក្នុងមូលដ្ឋានទិន្នន័យ ការចែកចាយទិន្នន័យព័ត៌មាន និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗទំនើប ។

ទស្សនកិច្ចទន្លេមីស៊ីស៊ីពី សហរដ្ឋអាមេរិក នាថ្ងៃទី ១៧-២៤ ខែសីហា ឆ្នាំ ២០១៩ ។ ប្រតិភូនៃប្រទេសជាសមាជិក គ.ទ.ម រួមមាន ៖ កម្ពុជា ឡាវ ថៃ និងវៀតណាម និងមន្ត្រីលេខាធិការដ្ឋាន គ.ទ.ម បានចូលរួមដោយសម្រេចបាននូវលទ្ធផល រួមមាន ៖ (១) ការចុះពិនិត្យសំណង់ហេដ្ឋារចនាសម្ព័ន្ធនាវា និងការទប់ទល់គ្រោះមហន្តរាយទឹកជំនន់ និងរលកសមុទ្រក្នុងអាងទន្លេមីស៊ីស៊ីពីប៉ែកខាងក្រោមក្នុងរដ្ឋ Louisiana (២) សិក្សាស្វែងយល់នៅមជ្ឈមណ្ឌលវិស្វកម្ម និងអភិវឌ្ឍន៍នៅទីក្រុង Vicksburg ក្នុងរដ្ឋ Mississippi និង (៣) កិច្ចជំនួបប្រជុំជាមួយប្រធាន និងសមាជិកគណៈកម្មការទន្លេមីស៊ីស៊ីពី និងចូលរួមអង្កេតការណ៍ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មការទន្លេមីស៊ីស៊ីពី ជាមួយប្រជាពលរដ្ឋ និងទស្សនកិច្ចទំនប់វារីអគ្គិនី Bonneville នៅលើទន្លេកូឡុំបៀរ ។

- **យន្តការមេគង្គ-គង្គា (Mekong-Ganga)**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចូលរួមកិច្ចប្រជុំពាក់ព័ន្ធយន្តការនេះ មួយចំនួន ក៏ប៉ុន្តែពុំទាន់មានជាសកម្មភាពគម្រោងជាក់លាក់ដែលទ្រទ្រង់ដោយយន្តការនេះនៅឡើយទេ ។

- **ក្រោមយន្តការគណៈកម្មការចម្រុះ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ឡាវ**

ការគ្រប់គ្រងជលផលឆ្លងដែនទន្លេសេកុង-មេគង្គ ដែលបានអនុវត្តរយៈពេល៥ឆ្នាំ ពីឆ្នាំ ២០១៦-២០២០ ក្រោមថវិកាធនាគារពិភពលោកតាមរយៈ គ.ទ.ម ដែលអនុវត្តដោយរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបានបញ្ចប់ នាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដោយសម្រេចបានសមិទ្ធផលក្នុងនោះ ភាគីកម្ពុជា និងឡាវ បានឯកភាព និងអនុម័តផែនការ ៥ឆ្នាំ និងលក្ខខណ្ឌការងារ សម្រាប់គ្រប់គ្រងជលផលឆ្លងដែន ក្នុងខែឧសភា ឆ្នាំ២០១៩។

- **ក្រោមយន្តការគណៈកម្មការចម្រុះ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-វៀតណាម**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានបន្តកិច្ចសហការជាមួយ គណៈកម្មាធិការជាតិទន្លេមេគង្គវៀតណាម ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តការទ្វេភាគី ក្នុងឆ្នាំ ២០១៩ ដោយបានចូលរួម ៖ (i) កិច្ចប្រជុំនៃក្រុមការងារជំនាញរួម លើកទី ១២ នាថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៩ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ។ ប្រតិភូប្រទេសទាំងពីរ បានពិភាក្សាបញ្ចប់សេចក្តីព្រាង បទប្បញ្ញត្តិ ស្តីពីការប្រើប្រាស់ធនធានទឹកតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម (ii) ចូប្រជុំគណៈកម្មការចម្រុះ កម្ពុជា-វៀតណាម លើកទី ១៧ នាថ្ងៃទី ២០-២១ ខែ សីហា ឆ្នាំ ២០១៩ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រាជធានីភ្នំពេញ ដោយក្នុងនោះ ការងារនៃគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសកម្ពុជា និងវៀតណាម បានឯកភាព ៖ (១) បន្តការប្តេជ្ញាចិត្ត ធ្វើការជាមួយគ្នាដើម្បីអនុវត្តការងារដែលទាក់ទងទៅនឹងបរិស្ថាន ធនធានទឹកនិងឧតុនិយម (២) បន្តពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៃការអភិវឌ្ឍ និងការប្រើប្រាស់ធនធានទឹកទន្លេមេគង្គ ស្របតាមកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ និងសេចក្តី

ថ្លែងការណ៍រួមក្រុងសៀមរាបឆ្នាំ ២០១៨ នៃកិច្ចប្រជុំកំពូល គ.ទ.ម លើកទី ៣ និង (៣) បន្តអនុវត្តគម្រោងឆ្លងដែនប្រកបដោយប្រសិទ្ធភាព ដែលគាំទ្រថវិកាពីធនាគារពិភពលោកក្នុងការជម្រុញកិច្ចសហប្រតិបត្តិការឆ្លងដែនរវាងប្រទេសកម្ពុជា និងវៀតណាម លើការគ្រប់គ្រង និងការអភិវឌ្ឍទឹក និងធនធានពាក់ព័ន្ធដទៃទៀតនៅក្នុងអាងទន្លេមេគង្គ ។

- **ក្រោមយន្តការគណៈកម្មការចម្រុះ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃ**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានបន្តកិច្ចសហការជាមួយ គណៈកម្មាធិការជាតិទន្លេមេគង្គថៃ ក្នុងការអនុវត្តគម្រោង ក្រោមក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងឆ្នាំ ២០១៩ រួមមាន៖ (i) គម្រោងសហប្រតិបត្តិ-ការនៅបឹងទន្លេសាបនៃប្រទេសកម្ពុជា និងអាងបឹងសុងក្លានៃប្រទេសថៃ ដែលនេះ ជាគម្រោងសាកល្បងប្រមូលព័ត៌មាន និងផ្លាស់ប្តូរបទពិសោធន៍ ដើម្បីរៀបចំរបាយការណ៍ និងផែនការអនុវត្តរួម ដោយផ្តោតលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជលផល និងការលើកកម្ពស់ស្ត្រី ។ គម្រោងនេះ ត្រូវបានបញ្ចប់ក្នុងខែ មេសា ឆ្នាំ ២០១៩ និង (ii) គម្រោងគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត នៅតំបន់ព្រំដែនកម្ពុជា-ថៃ ដែលគាំទ្រថវិកាដោយអង្គការ GIZ ។ គម្រោងនេះ ត្រូវបានបញ្ចប់នូវជំហានទី១ ក្នុងពេលថ្មីៗនេះ ហើយបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយទៅដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នាថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៩ នៅខេត្តបន្ទាយមានជ័យ ។ បន្ទាប់ពីកិច្ចប្រជុំថ្នាក់តំបន់នាថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៩ នៅទីក្រុងវៀងច័ន្ទ អង្គការ GIZ នឹងបន្តគម្រោងគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត នៅតំបន់ព្រំដែនកម្ពុជា-ថៃ ដំណាក់កាលទី២ ឆ្នាំ ២០២០-២០២១ ។

- **កិច្ចសហប្រតិបត្តិការ រវាងកម្ពុជា និងសហភាពអឺរ៉ុប**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានពិនិត្យ និងផ្តល់ជូននូវរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហ-ប្រតិបត្តិការ កម្ពុជា-សហភាពអឺរ៉ុប ដើម្បីត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុប លើកទី ១១ មានដូចខាងក្រោម៖

ចាប់ពីឆ្នាំ ២០០៣ ដល់ឆ្នាំ ២០១៨ សហភាពអឺរ៉ុប (EU) បានជួយឧបត្ថម្ភគាំទ្រថវិកាដល់ គ.ទ.ម មានទឹកប្រាក់សរុបប្រមាណ ៦.៤ លានដុល្លារអាមេរិក សម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ គ.ទ.ម ក្នុងនោះ លើផ្នែកសំខាន់ៗរួមមាន ៖ ភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ (Climate Change Adaptation), ការសិក្សាវាយតម្លៃភាពងាយរងគ្រោះ និងការពិនិត្យតាមដានផលប៉ះពាល់សង្គម (Social Impact Monitoring and Vulnerability Assessment), ការពិនិត្យតាមដានជលផល (Fisheries monitoring), ការពិនិត្យតាមដានសុខុមាលភាពអេកូឡូស៊ី (Ecological Health Monitoring), ការពិនិត្យតាមដាន គុណភាពទឹក (Water quality monitoring), ការពិនិត្យតាមដានកករដី (Sediment monitoring), ការពិនិត្យតាមដានកំពស់ទឹក (Water level monitoring), ការងារអភិបាលកិច្ច (Governance), ការចូលរួមរបស់ភាគីពាក់ព័ន្ធ (Stakeholder engagements) និងការត្រៀមបង្ការទឹកជំនន់ (Flood preparedness) ។

សម្រាប់ឆ្នាំ ២០១៩-២០២០ សហភាពអឺរ៉ុប បានផ្តល់ថវិកាចំនួន ៥លាន អឺរ៉ូ បន្ថែមទៀតដល់ គ.ទ.ម សម្រាប់អនុវត្តបណ្តាសកម្មភាពទាំងឡាយនៃផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១៦-២០២០ ដែលសកម្មភាពសំខាន់ៗទាំងនោះ រួមមាន៖ ការពិនិត្យតាមដានជលផល (Fisheries monitoring), ការពិនិត្យតាមដានកករដី (Sediment monitoring), ការបង្កើតប្រពន្ធ័តាមដាន និងវាយតម្លៃការងារ (M&E), ការរៀបចំមូលដ្ឋានទិន្នន័យសេដ្ឋកិច្ច-សង្គម និងការសិក្សាវាយតម្លៃភាពងាយរងគ្រោះ និងការពិនិត្យតាមដានផលប៉ះពាល់សង្គម (Socio-economic database and SIMVA), ការពិនិត្យតាមដានគុណភាពទឹក (Water quality monitoring), វេទិកាអ្នកពាក់ព័ន្ធ (Stakeholder forum), ការព្យាករទឹកជំនន់ (Flood forecasting), ប្រព័ន្ធអេកូឡូស៊ី និងដីសើម (Ecosystem and Wetland), ទឹក និងអាកាសធាតុ (Water and Climate) ការអង្កេតរូបភាពពីលំហអាកាស និងការធ្វើផែនទី (Remote Sensing) និងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធហិរញ្ញវត្ថុ (improvement of financial systems) ។

- **ចូលរួមក្នុងកិច្ចកំណែទម្រង់ក្នុងក្របខណ្ឌគណៈកម្មការទន្លេមេគង្គ MRC**

គណៈកម្មការទន្លេមេគង្គ បានបន្តអនុវត្តន៍ការកែទម្រង់របស់ខ្លួន ស្របតាមផែនការវិមជ្ឈការមុខងារស្នូល ដែលជាផែនការគន្លឹះសម្រាប់ការអនុវត្ត តាមសេចក្តីសម្រេចិត្តរបស់ប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិក MRC ក្នុងកិច្ចប្រជុំកំពូលលើកទី១ នៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១០ នៅហួរហ៊ិន ប្រទេសថៃ ដែលបានប្តេជ្ញាថានឹងធានានូវស្វ័យហិរញ្ញវត្ថុ នៅក្នុងឆ្នាំ ២០៣០ ខាងមុខ ដើម្បី MRC ក្លាយជាអន្តររដ្ឋាភិបាល ដែលធ្វើការផ្ទាល់ជាមួយរាជរដ្ឋាភិបាលប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម លើការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពរួមគ្នានូវធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ។

- **ចូលករួមក្នុងការអនុវត្តវិមជ្ឈការមុខងារស្នូលក្នុងក្របខណ្ឌ MRC ជំហាន២**

ស្របតាមផែនការវិមជ្ឈការមុខងារស្នូល ការធ្វើវិមជ្ឈការនឹងត្រូវបានធ្វើឡើងជា ៣ ជំហាន ក្នុងនោះ ជំហានទី១ ពីឆ្នាំ ២០០៩-២០១៥ រួមមាន ៥សកម្មភាព ជំហានទី២ ពីឆ្នាំ ២០១៦-២០២០ មាន ៩សកម្មភាព និងជំហានទី៣ ពីឆ្នាំ ២០២១-២០៣០ មាន ៣សកម្មភាព។ ក្នុងឆ្នាំ ២០១៩ នៅតែបន្តការអនុវត្តការងារតាមផែនការដែលបានកំណត់ក្នុងជំហានទី២ ដែលមានសកម្មភាព ៩ ត្រូវធ្វើវិមជ្ឈការ ដោយការកាត់បន្ថយការទ្រទ្រង់ថវិកាជាជំហានៗ រហូតដល់ការធ្វើវិមជ្ឈការពេញលេញក្នុងឆ្នាំ ២០២០ រួមមាន ការត្រួតពិនិត្យសុខភាពប្រព័ន្ធអេកូឡូស៊ី ការតាមដានផ្នែកជលផល ការប្រមូលទិន្នន័យសម្រាប់ការវាយតម្លៃស្ថានភាពសង្គម និងភាពងាយរងគ្រោះ និងការកសាងផែនការចង្អុលថ្នាក់ជាតិ ។ ការងាទាំងនេះនឹងជាបន្ទុករបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងផែនការ ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។ ក្រសួងស្ថាប័នពាក់ព័ន្ធបានខិតខំអនុវត្តវិមជ្ឈការតាមផែនទីវិថីដែលបានកំណត់ ដោយទទួលបានលទ្ធផលជាវិជ្ជមានមួយចំនួន តែក្នុងនោះ នៅមានការជួបប្រទះនូវបញ្ហាប្រឈមជាច្រើនរួមមាន បញ្ហាហិរញ្ញវត្ថុ និងធនធានមនុស្សជាដើម ។

- **ចូលរួមក្នុងការអនុវត្តនីតិវិធីប្រើប្រាស់ទឹករបស់ MRC**

ការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ ឲ្យកាន់តែមានប្រសិទ្ធិភាព ក្នុងគ្រាដែលមានភាពចាំបាច់ ការអនុវត្តន៍នីតិវិធីទាំង ៥ កាន់តែចាំបាច់ ក្នុងនោះ ១-នីតិវិធីស្តីពីការដោះដូរ និងចែករំលែកទិន្នន័យ និងព័ត៌មាន ២-នីតិវិធីស្តីពីត្រួតពិនិត្យការប្រើប្រាស់ទឹក ៣-នីតិវិធីស្តីពីការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ៤-នីតិវិធីស្តីពីការរក្សាធារទឹកក្នុងទន្លេមេ និង ៥-នីតិវិធីស្តីពីគុណភាពទឹក ព្រមទាំងគោលការណ៍ណែនាំបច្ចេកទេសមួយចំនួន សម្រាប់សម្រួលដល់ការអនុវត្តនីតិវិធីទាំង ៥ នោះ ។ ដើម្បីសម្រួលការងារអនុវត្តន៍នីតិវិធីទាំង ៥នេះ គណៈកម្មការទន្លេមេគង្គ បានបង្កើតឡើងនូវវេទិការួម (Joint Platform) ដើម្បីប្រមូលផ្តុំនូវការចូលរួម និងមតិយោបល់ពីតំណាងជាន់ខ្ពស់ និងក្រុមជំនាញការនៃប្រទេសជាសមាជិក និងលេខាធិការដ្ឋាន ក្នុងការពិនិត្យ និងពិភាក្សារកវិធីសាស្រ្ត យុទ្ធសាស្រ្ត និងការណែនាំនានា ដើម្បីសម្រេចការអនុវត្តនីតិវិធីទាំងនោះ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៃអាងទន្លេមេគង្គ ។ ការអនុវត្តនូវនីតិវិធីទាំងនេះ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ជាពិសេសលើការងាររៀបចំបញ្ចប់នូវគោលការណ៍ណែនាំ និងយុទ្ធសាស្រ្តពាក់ព័ន្ធមួយចំនួន ដែលពុំទាន់ទទួលការឯកភាពគ្នា ។

**ក្នុង ឆ្នាំ ២០១៩ បណ្តានីតិវិធីទាំង ៥ បានដំណើរការអនុវត្ត ដោយសម្រេចបាន ដូចខាងក្រោម៖**

- **ការអនុវត្តនីតិវិធី PMFM** ដើម្បីតាមដាន និងប្រើប្រាស់ទិន្នន័យព័ត៌មានពីគេហទំព័ររបស់លេខាធិការដ្ឋាន គ.ទ.ម សម្រាប់ការរាយការណ៍ ផ្ទៀងផ្ទាត់ និងធ្វើរបាយការណ៍ ។ ការអនុវត្តនីតិវិធី សម្រេចបានរួមមាន៖ (១) បានចូលរួមសិក្ខាសាលា និងបណ្តុះបណ្តាលការងារម៉ូដែលនៅថ្នាក់ជាតិ និងបានចាត់មន្ត្រីចូលរួមការងារម៉ូដែលនៅថ្នាក់តំបន់ (២) ចាត់បញ្ជូនមន្ត្រី ០១ រូប ជាជំនួយការផ្នែកម៉ូដែល នៅលេខាធិការដ្ឋាន គ.ទ.ម សម្រាប់រយៈពេល ១១ ខែ ក្នុងឆ្នាំ ២០២០ (៣) បានពិភាក្សាជាមួយប្រទេសជាសមាជិកផ្សេងទៀត

លើការប្រើប្រាស់ឧបករណ៍ម៉ូដែល និងលើគម្រោងសិក្សាសាកល្បងសម្រាប់ពិនិត្យតាមដានការប្រើប្រាស់ទឹក និង (៤) បានរៀបចំមូលដ្ឋានចំណេះដឹងថ្នាក់ជាតិ សម្រាប់ជួយដល់ការងារសម្របសម្រួលបច្ចេកទេស ។

- **ការអនុវត្តនីតិវិធី PDIES** ដោយបានពិភាក្សាលើការងារសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងការងារទិន្នន័យ និងព័ត៌មាន រួមមាន (១) ពិនិត្យ ជួសជុល ថែទាំ និងដាក់ឲ្យដំណើរការឡើងវិញស្ថានីយជលសាស្ត្រ ឧតុនិយមទាំង ១២ កន្លែង នៅតាមបណ្តាខេត្តទូទាំងប្រទេស (២) ធ្វើឲ្យដំណើរឡើងវិញ និងការធ្វើទំនើបកម្មប្រព័ន្ធព័ត៌មាននៅថ្នាក់តំបន់ និងថ្នាក់ជាតិ (៣) រៀបចំផែនទីគម្របដី និងគម្របព្រៃឈើ ឆ្នាំ២០២០ នៅកម្ពុជា សម្រាប់អាងទន្លេមេគង្គភាគខាងក្រោម (៤) សហការប្រមូល និងផ្តល់ទិន្នន័យទៅឲ្យលេខាធិការដ្ឋាន គ.ទ.ម ដើម្បីប្រើប្រាស់ ក្នុងការងារធ្វើបច្ចុប្បន្នភាពមូលដ្ឋានចំណេះដឹង ការងារម៉ូដែល និងព្យាករណ៍ទឹកជំនន់ និង (៥) គិតគូរលើការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីទុកដាក់ទិន្នន័យ តាមក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ។

- **ការអនុវត្តនីតិវិធី PMFM** សម្រេចបាន រួមមាន៖ (១) ការប្រើប្រាស់ទិន្នន័យ ព័ត៌មាន សម្រាប់ការរៀបចំរបាយការណ៍ស្តីពីស្ថានភាពទឹកតាមដងទន្លេមេគង្គ ក្នុងអាងទន្លេមេគង្គភាគខាងក្រោម និងរៀបចំរបាយការណ៍ ជូនថ្នាក់ដឹកនាំ គ.ជ.ទ.ម.ក ជ្រាប (២) ការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មានពីប្រភពផ្សេងទៀតរបស់ គ.ទ.ម ក្នុងនោះ ផ្ទៀងផ្ទាត់ទិន្នន័យ និងប្រើប្រាស់ឧបករណ៍បច្ចេកទេសពី មជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតថ្នាក់តំបន់ និងប្រភពដទៃទៀតដែលអាចជឿទុកចិត្តបាន ដើម្បីសន្និដ្ឋាន និងកំណត់អនុសាសន៍ ។

- **ការអនុវត្តនីតិវិធី PNPCA** បានដំណើរពិគ្រោះយោបល់ជាមុន លើសំណើគម្រោងវារីអគ្គិសនីលួងប្រាបាង (LPHPP) របស់ឡាវ នៅលើទន្លេមេ ដោយសម្រេចបាន៖ (១) សេចក្តីព្រាងរបាយការណ៍វាយតម្លៃ និងកំណត់វិសាលភាពនៃការសិក្សា ពិនិត្យរបាយការណ៍បច្ចេកទេសឡើងវិញ (TRR) លើសំណុំឯកសារ LPHPP (២) សេចក្តីព្រាងឯកសាររបាយការណ៍សិក្សាពិនិត្យបច្ចេកទេសឡើងវិញលើកទី១ និងទី២ លើសំណុំឯកសារ LPHPP (៣) ឯកសារសង្ខេប នៃរបាយការណ៍សិក្សាពិនិត្យបច្ចេកទេសឡើងវិញលើកទី២ (ខ្មែរ និងអង់គ្លេស) និងសេចក្តីព្រាងចុងក្រោយនៃរបាយការណ៍សិក្សា ពិនិត្យបច្ចេកទេសឡើងវិញ ។

- **ចូលរួមក្នុងការងារគម្រោងប្រើប្រាស់ទឹក និងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី**

គម្រោងទំនប់វារីអគ្គិសនីនៅលើទន្លេមេ នៃទន្លេមេគង្គ (ទន្លេឡានឆាង) ក្នុងទឹកដីចិនដែលជាប្រទេសដៃគូសន្ទនាមួយក្នុងក្របខណ្ឌ គ.ទ.ម គឺមាន ចំនួន ៨ ដែលក្នុងនោះ គម្រោងចំនួន ៦ បាននឹងកំពុងប្រតិបត្តិការ គម្រោងមួយកំពុងដំណើរការសាងសង់ និងមួយទៀតត្រូវបានផ្អាកទៅវិញ ។ ថាមពលផលិតសរុបចេញពីគម្រោងវារីអគ្គិសនីទាំងនោះ មានចំនួនប្រមាណ ១៥.០០០ មេហ្គាវ៉ាត់ ។ គ.ទ.ម បាន និងកំពុងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយចិន លើការផ្លាស់ប្តូរបច្ចេកទេស ការចែករំលែកទិន្នន័យ និងព័ត៌មាន និងកិច្ចប្រតិបត្តិការនៃទំនប់វារីអគ្គិសនី នៅលើទន្លេឡានឆាង ដើម្បីកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរ មកលើទន្លេមេគង្គភាគខាងក្រោម ។ ការអភិវឌ្ឍវារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម កំពុងតែមានសន្ទុះទៅមុខគួរឲ្យកត់សម្គាល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលចេះតែកើនឡើងផ្នែកថាមពល បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ច នៃប្រទេសតាមដងទន្លេមេគង្គ ។ ការអភិវឌ្ឍលើផ្នែកនេះ ក៏អាចបង្កជាផលប៉ះពាល់ និងហានិភ័យធ្ងន់ធ្ងរមកលើបរិស្ថាន និងសង្គមផងដែរ ប្រសិនបើពុំមានការសិក្សាឲ្យបានគ្រប់ជ្រុងជ្រោយ និងគ្រប់គ្រងឲ្យមានប្រសិទ្ធភាពទេនោះ ។ នៅលើដងទន្លេមេគង្គភាគខាងក្រោម មានគម្រោងវារីអគ្គិសនីទាំងអស់ចំនួន ១១គម្រោង ដែលក្នុងនោះ នៅលើដងទន្លេមេគង្គក្នុងទឹកដីឡាវ មានចំនួន ៩ គម្រោង (គម្រោងចំនួន ៧ ជាគម្រោងដែលស្ថិតនៅលើដងទន្លេមេគង្គមេ ក្នុងទឹកដីឡាវ និងគម្រោងចំនួន ២ ជាគម្រោងដែលស្ថិតនៅដងទន្លេមេគង្គ ជាព្រំដែនរួមឡាវ-ថៃ) និងគម្រោងចំនួន ២ ជាគម្រោងនៅលើដងទន្លេមេគង្គក្នុងទឹកដីកម្ពុជា (គម្រោងស្ទឹងត្រែង និងសំបូរ) ។

ជាការជួយសម្រួលដល់ការគិតគូរអំពីនិរន្តរភាពនៃការអភិវឌ្ឍ គ.ទ.ម បានបង្កើតនូវយន្តការគតិយុត្តិមួយចំនួន ដើម្បីវាយតម្លៃផលប៉ះពាល់ និងបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់ទាំងនោះ រួមមាន ឯកសារវាយតម្លៃបរិស្ថានបែបយុទ្ធសាស្ត្រ ការវាយតម្លៃផលប៉ះពាល់ជាបណ្តុំ យុទ្ធសាស្ត្រអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយនិរន្តរភាព គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងហានិភ័យ និងកាត់បន្ថយផលប៉ះពាល់ផ្នែកបរិស្ថានពីគម្រោងវារីអគ្គិសនី គោលការណ៍ណែនាំសម្រាប់គ្រោងប្លង់វារីអគ្គិសនីលើទន្លេមេ ឧបករណ៍វាយតម្លៃដោយរហ័សនិរន្តរភាពវារីអគ្គិសនី ផែនការសកម្មភាពរួមគ្នានិងការពិនិត្យតាមដានបរិស្ថានរួមគ្នា សម្រាប់គម្រោងនៅលើដងទន្លេមេ និងសេចក្តីថ្លែងការណ៍រួម ។

ក្នុងឆ្នាំ ២០១៩ ដំណើរការងារសម្រេចបានលទ្ធផល រួមមាន (i) ធ្វើបច្ចុប្បន្នភាព គោលការណ៍ណែនាំសម្រាប់គ្រោងប្លង់វារីអគ្គិសនីលើទន្លេមេ និងបានដាក់ជូនគណៈកម្មាធិការរួម ដើម្បីអនុម័តក្នុងកិច្ចប្រជុំរបស់ខ្លួនលើកទី ៤៩ និង (ii) បានរៀបចំកិច្ចពិគ្រោះយោបល់ និងសិក្ខាសាលាបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីសេចក្តីព្រាងយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយនិរន្តរភាព នាថ្ងៃទី ២៧-២៨ ខែ មិថុនា ឆ្នាំ ២០១៩ ។

- **ចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេ និងផែនការអាងទន្លេ**

យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង រយៈពេល ៥ ឆ្នាំ ២០១៦-២០២០ បានរៀបចំឡើងតាមដំណើរការកសាងផែនការចម្រុះ ដោយមានការចូលរួមពីភាគីសំខាន់ៗជាច្រើនចម្រុះគ្នា និងចម្រុះវិស័យ ដែលដឹកនាំដោយប្រទេសជាសមាជិក គ.ទ.ម និងត្រូវបានអនុវត្តនៅកម្រិតតំបន់ ជាតិ និងអាងទន្លេ ។

នៅក្នុងឆ្នាំ២០១៩ សមិទ្ធផលសំខាន់ៗដែលគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានដឹកនាំ និងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ដោយសម្រេចបានលទ្ធផល រួមមាន ៖

.បានដាក់បញ្ចូលគម្រោងសហប្រតិបត្តិការចំនួន៤ ក្នុងផែនការចង្អុលថ្នាក់ជាតិ ឆ្នាំ ២០១៦-២០២០ ដោយក្នុងនោះ គម្រោងជាតិ មាន ១គម្រោង និងសកម្មភាពជាតិមាន ២គម្រោង ទៅក្នុងផែនការរំកិលជាតិ ឆ្នាំ ២០១៩-២០២១ និងបានផ្សព្វផ្សាយនៅថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីគៀងគររកថវិកាសម្រាប់អនុវត្ត ។ គម្រោងសហប្រតិបត្តិការចំនួន ២ ដែលគាំទ្រថវិកាដោយ GIZ ត្រូវបាននិងបន្តអនុវត្តគឺ ៖ (១) ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតឆ្លងដែន នៅតំបន់ព្រំដែនកម្ពុជា-ថៃ (ផ្នែកនៃអនុតំបន់ 9C-9T) និង (២) ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកឆ្លងដែនកម្ពុជា-ឡាវ នៅតំបន់ល្បាក់ខោន រួមទាំងការត្រួតពិនិត្យផលប៉ះពាល់ឆ្លងដែនពីគម្រោងវារីអគ្គិសនី ដន សាហុង របស់ឡាវ នៅលើទន្លេមេ ។

.បានផ្សព្វផ្សាយអំពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រជាអាទិភាពនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ឆ្នាំ ២០១៦-២០២០ របស់ គ.ទ.ម និងមេរៀននិងបទពិសោធន៍ពីយន្តការ ថ្នាក់តំបន់នានា ដូចជា ASEAN, GMS, MLC ជាដើម ។ល។

.បានពិភាក្សា និងផ្តល់ធាតុចូលសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ គ.ទ.ម និងផែនការចង្អុលថ្នាក់ជាតិ សម្រាប់រយៈពេល ៥ឆ្នាំ ខាងមុខ (២០២១-២០២៥) ដែលត្រូវចាប់ផ្តើមរៀបចំក្នុងឆ្នាំ២០២០ ។

.បានពិភាក្សា និងផ្តល់ធាតុចូល អំពីការគិតលើចក្ខុវិស័យ យុទ្ធសាស្ត្រជាអាទិភាព និងលទ្ធផលរួមនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង សម្រាប់រយៈពេល១០ឆ្នាំ (២០២១-២០៣០) ដែលត្រូវរៀបចំក្នុងឆ្នាំ ២០២០។

- **ចូលរួមក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានទ្វេភាគី**

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានដឹកនាំ និងសម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានគឺគម្រោងគ្រប់គ្រងធនធានទឹកចម្រុះមេគង្គ តំណាក់កាលទី៣ សម្រាប់កម្ពុជា IDA Credit No. 5777-KH មានទឹកប្រាក់ ១៥ លានដុល្លារអាមេរិក ដោយរាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក បានចុះកិច្ចព្រមព្រៀងនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ សម្រាប់អនុវត្តរយៈពេល ៥ឆ្នាំ (២០១៦-២០២១) ។ គ.ជ.ទ.ម.ក ជាស្ថាប័ន

ដឹកនាំប្រតិបត្តិគម្រោងនេះ ដែលចែកជាសមាសភាគចំនួន ២ គឺ៖ ទី១) គម្រោងគ្រប់គ្រងធនធានជលផល និងវារីវប្បកម្ម មានថវិកាចំនួន ១០ លានដុល្លារអាមេរិក ដែលអនុវត្តដោយរដ្ឋបាលជលផល នៅភូមិភាគឦសាន និងទី២) គម្រោងគ្រប់គ្រងធនធានទឹកចម្រុះមេគង្គនៅតំបន់ភូមិភាគឦសាន មានថវិកាចំនួន ៥ លានដុល្លារអាមេរិក ដែលអនុវត្តដោយ គ.ជ.ទ.ម.ក និងមានការចូលរួមពីនាយកដ្ឋានជំនាញពាក់ព័ន្ធ នៃក្រសួងធនធានទឹក និងឧតុនិយម ។

**ក្នុងឆ្នាំ ២០១៩ គម្រោង បានដំណើរការងារ និងសម្រេចបានសមិទ្ធផល រួមមាន៖**

.បាន និងកំពុងរៀបចំបង្កើតប្រព័ន្ធគាំទ្រការធ្វើសេចក្តីសម្រេច និងបណ្តាម៉ូដែលជលសាស្ត្រសម្រាប់អាងទន្លេ (សេកុង-សេសាន-ស្រែពក ឬ 3S និង អាងព្រែកទាំង៤ ឬ 4P (ព្រែកព្រះ ព្រែកគ្រៀង ព្រែកកាំពី និងព្រែកទេ) តាមរយៈការកសាងបាននូវឯកសារបច្ចេកទេស ចំនួន ២ និងបានពិភាក្សាក្នុងកិច្ចប្រជុំបច្ចេកទេស ចំនួន ៤ លើក ។

.បាន និងកំពុងរៀបចំម៉ូដែលចំនួន ៤ ដែលក្នុងនោះ ម៉ូដែលចំនួន ២ សម្រាប់អាងទន្លេ សេសាន និងស្រែពក (ជាអាងទន្លេឆ្លងដែនជាមួយប្រទេសវៀតណាម) និងម៉ូដែលចំនួន ២ ទៀត សម្រាប់អាងទន្លេ ២ និងអាងព្រែកទាំង៤។

.បាន និងកំពុងរៀបចំឯកសារសម្រាប់ការងារគ្រប់គ្រងអាងទន្លេឆ្លងដែលដែលជួយគាំទ្រដល់យន្តការនៃការងារសម្របសម្រួលលើការគ្រប់គ្រងធនធានទឹកឆ្លងដែនជាមួយប្រទេសវៀតណាម នៅក្នុងតំបន់អាងទន្លេសេសាន ស្រែពក ដោយមានការគាំទ្រពីគម្រោងប្រទេសកម្ពុជា និងវៀតណាម នឹងឈានដល់ការព្រមព្រៀងលើប្រភេទទិន្នន័យ ដែលត្រូវបានចែករំលែក និងឯកភាពគ្នាលើនីតិក្រមនៃការចែករំលែកព័ត៌មាន ដែលអាចគាំទ្រដោយ គ.ទ.ម ។ ប្រភេទនៃទិន្នន័យ ដែលត្រូវធ្វើការចែករំលែកនោះរួមមាន៖ i) ទិន្នន័យជលសាស្ត្រ ii) ទិន្នន័យឧតុនិយម និង iii) ទិន្នន័យដែលបានមកពីដំណើរការម៉ូដែល ។

.បាន និងកំពុងរៀបចំក្របខណ្ឌម៉ូដែលជលសាស្ត្រ សម្រាប់អាងទន្លេទាំងបី (3S) និងអាងព្រែកទាំងបួន (4P) សម្រាប់ DSS ដំណាក់កាលទី១ ។

.បាន និងកំពុងសិក្សាផ្នែកបច្ចេកទេស ដើម្បីជួយគាំទ្រដល់ការបង្កើតស្ថានីយថ្មី តាមដានត្រួតពិនិត្យជលសាស្ត្រ និងឧតុនិយម ឬការជួសជុលដាក់ឲ្យដំណើរការឡើងវិញនៃស្ថានីយជលសាស្ត្រ និងឧតុនិយម ដែលមានស្រាប់នៅក្នុងអាងទន្លេសេកុង-សេសាន-ស្រែពក និងក្នុងអាងព្រែកទាំង ៤ សរុបចំនួន ២៥ ស្ថានីយ ក្នុងនោះមាន៖ស្ថានីយជលសាស្ត្រចំនួន ១០, ស្ថានីយឧតុនិយម ចំនួន៤, ស្ថានីយវាស់ទឹកភ្លៀង ចំនួន ១០, និងស្ថានីយសម្រាប់តាមដាន និងត្រួតពិនិត្យគុណភាពទឹក ចំនួន ១ ដែលទីតាំងស្ថានីយទាំងនោះ មាននៅក្នុងរបាយការណ៍កំណត់ទីតាំងស្ថានីយជលសាស្ត្រ និងឧតុនិយម ដែលបានស្នើសុំដោយមន្ទីរនៃខេត្តទាំង៤ ផ្អែកលើតម្រូវការបច្ចេកទេសជាក់ស្តែង ។

ក្រុមការងារគម្រោងបាន៖ (១) ចុះបេសកកម្មវាយតម្លៃស្ថានភាពទីតាំងគម្រោងចំនួន ២ លើក ដើម្បីសិក្សា និងផ្ទៀងផ្ទាត់ទីតាំងស្ថានីយជលសាស្ត្រ និងឧតុនិយម នៅខេត្តគោលដៅទាំងបួន ដោយជំនាញការរបស់ក្រុមហ៊ុន DHI និងសហការជាមួយសមាជិកនៃអនុក្រុមម៉ូដែលគ្រប់គ្រងធនធានទឹក (២) សិក្សា និងផ្តល់មតិយោបល់លើឯកសារទស្សនៈទាននៃការធ្វើឲ្យប្រសើឡើងនៃប្រព័ន្ធជលសាស្ត្រ និងឧតុនិយម និងឯកសារទស្សនទាននៃការបង្កើតប្រព័ន្ធគាំទ្រការធ្វើសេចក្តីសម្រេច ដែលបានរៀបចំដោយក្រុមហ៊ុនជំនាញការ DHI

(៣) បំពេញទស្សនកិច្ច ដើម្បីលើកកម្ពស់ការយល់ដឹងរបស់មូលដ្ឋាន អំពីការសង្កេតកម្រិត និងលំហូរទឹកនៃអាងទន្លេទាំងបី (3S)។

- **ចូលរួមអនុវត្តផ្នែកបបនីយជីវមណ្ឌលបឹងទន្លេសាប**

ក្នុងឆ្នាំ ២០១៩ លើការងារបបនីយជីវមណ្ឌលបឹងទន្លេសាប, គ.ជ.ទ.ម.ក បានបំពេញភារកិច្ច និងសម្រេចបានលទ្ធផលការងាររួមមាន (i) ព័ត៌មានពាក់ព័ន្ធនឹងបបនីយជីវមណ្ឌលបឹងទន្លេសាប បានបន្តប្រមូល ចងក្រង និងធ្វើបច្ចុប្បន្នភាព (ii) សម្របសម្រួល និងចូលរួមគាំទ្រការសិក្សាសាកល្បងលើការអនុវត្តវិធីសាស្ត្រសារពើភ័ណ្ឌដីសើមនៅតំបន់រ៉ាមសារព្រែកទាល់ (iii) បានចូលរួមសហការក្នុងការផ្តល់ធាតុចូល សម្រាប់រៀបចំរបាយការណ៍ស្តីពីស្ថានភាពដីសើម ក្នុងអាងទន្លេមេគង្គភាគខាងក្រោម និង (iv) បានពិនិត្យ រៀបចំដើម្បីចងក្រងព័ត៌មានបច្ចុប្បន្នភាព ស្តីពីស្ថានភាពបបនីយជីវមណ្ឌលបឹងទន្លេសាប និងរៀបចំផែនការ និងសកម្មភាពការងារ ដើម្បីជម្រុញការអនុវត្តឲ្យមានប្រសិទ្ធភាព ។

## គ.២- កម្មវិធីការគ្រប់គ្រងរដ្ឋបាល និងសេវាទូទៅ

នៅក្នុងឆ្នាំ ២០១៩ នេះ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចូលរួមអនុវត្តតាមកម្មវិធីកែលម្អលើការងារគ្រប់គ្រង រដ្ឋបាល និងអភិវឌ្ឍធនធានមនុស្ស ដូចខាងក្រោម ៖

- បានទទួលលិខិតពីក្រសួង និងស្ថាប័ននានា និងពីលេខាធិការដ្ឋាន MRC ប្រទេសជាសមាជិក MRC អង្គការដៃគូនានា ចំនួន ៥៣២ ច្បាប់
- បានបញ្ជូនឯកសារ និងលិខិតចេញទៅក្រសួងស្ថាប័ន ចំនួន ១.៣១១ ច្បាប់ និងទៅលេខាធិការដ្ឋាន MRC ប្រទេសជាសមាជិក MRC អង្គការដៃគូនានា ចំនួន ៣០ ច្បាប់
- បានទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងទទួលភ្ញៀវជាតិ និងអន្តរជាតិ ចំនួន ២៥ លើក
- បានចាត់ចែងជួយរៀបចំសោហ៊ុយបេសកកម្មក្នុងប្រទេសជូនមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ចុះពិនិត្យសិក្សាប្រមូលចងក្រងទិន្នន័យព័ត៌មាន បរិស្ថាន សេដ្ឋកិច្ច-សង្គម ជលផល របបទឹកទន្លេ គុណភាពទឹក នៅខេត្តតាមដងទន្លេមេគង្គ ទន្លេសាប និងដៃទន្លេដទៃទៀត ចំនួន ២៨ ក្រុមការងារ ។
- បានជួយសម្របសម្រួលជូនថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ចូលរួមកិច្ចប្រជុំ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិជាមួយក្រសួងស្ថាប័នជំនាញពាក់ព័ន្ធចំនួន ៥៧ លើក និង ទៅចូលរួមប្រជុំ សិក្ខាសាលា និងវេទិកាថ្នាក់តំបន់ ចំនួន ៦៨ លើក ។
- បានរៀបចំសម្របសម្រួលការងារផ្ទេរថវិកាបង់វិភាគទានជូនគណៈកម្មការទន្លេមេគង្គសម្រាប់ឆ្នាំ ២០១៩ ចំនួន ២.៨៨៣ លានរៀល ( 718.273 ដុល្លារអាមេរិក)
- បានគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការចំនួន ៣៥រូប និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១៥ រូប
- បានចាត់ចែងមន្ត្រីរាជការក្រោមឱវាទអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ទៅចូលរួមវគ្គបណ្តុះបណ្តាល នៅលេខាធិការដ្ឋាន MRC ចំនួន ២ នាក់ បណ្តុះបណ្តាលនៅចិន ចំនួន ៣ នាក់ នៅប្រទេសញ៉ូហ្សេឡែន ០១ រូប ។
- បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញគ្រប់គ្រប់ធនធានទឹក និងនីតិវិធីប្រើប្រាស់ទឹក និងការគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងសារព័ត៌មាន និងទំនាក់ទំនង ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ចំនួន ០៤ លើក មានមន្ត្រីចូលរួម ១០០ នាក់ ។

### ៣-បញ្ហាប្រឈម ៖

#### ក-ក្រសួងធនធានទឹក និងឧតុនិយម ៖

បញ្ហា និងឧបសគ្គមួយចំនួន ដែលបានរារាំងដល់ក្រសួងធនធានទឹក និងឧតុនិយម មិនអាចសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក៏ដូចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិមាន ៖

- ការផ្តល់ថវិកាលើការងារជួសជុល ស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រមានការយឺតយ៉ាវនឹងពុំចំរដូវកាលសាងសង់ ព្រមទាំងនៅមានកម្រិតដែលពុំអាចឆ្លើយតមតាមតម្រូវការជាក់ស្តែង
- ថវិកាលើការងារជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតទាប
- ការចូលរួមរបស់កសិករលើការងារប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតទាប

#### ខ-អាជ្ញាធរទន្លេសាប ៖

ឆ្លងតាមការត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ២០១៩ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានឆ្លុះបញ្ចាំងឲ្យឃើញពីបញ្ហាធំៗមួយចំនួន ដែលជាបញ្ហាប្រឈមចំពោះដំណើរការអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋាននីមួយៗ និងមិនអាចសម្រេចបានជោគជ័យទាំងស្រុងបានទៅតាមសកម្មភាពការងារ ដែលបានលើកឡើងក្នុងផែនការសកម្មភាពការងារប្រចាំឆ្នាំ ២០១៩ ។

បញ្ហាប្រឈម ទាំងនោះរួមមាន ៖

- សមត្ថភាពចំណេះដឹង និងបទពិសោធន៍ការងាររបស់មន្ត្រីរដ្ឋបាល និងបច្ចេកទេស នៅមានកម្រិត ទាំងការទទួលខុសត្រូវ និងការអនុវត្តការងារ
- សម្ភារបច្ចេកទេស ចុះអនុវត្តន៍ការងារ នៅមានការខ្វះខាត
- ការផ្តល់កិច្ចសហប្រតិបត្តិការ អាជ្ញាធរដែនដី និងមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធ នៅមានកម្រិតដោយសារការបាត់បង់ផលប្រយោជន៍ផ្ទាល់ខ្លួនពីឈ្មួញ
- សកម្មភាពការងារ ដែលបានលើកឡើងមានលក្ខណៈបច្ចេកទេស ដែលប៉ះពាល់ដល់ទំហំថវិកាពេលវេលា និងសមត្ថភាពមន្ត្រី មិនអាចសម្រេចបានជោគជ័យគ្រប់សកម្មភាពទាំងស្រុង ។

#### គ-គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ៖

- សមត្ថភាព ចំណេះដឹង និងជំនាញព្រមទាំងកំរិតនៃការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុកគម្រោង/កម្មវិធីបំរើការនៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក នៅមានកម្រិតនៅឡើយក្នុងខណៈពេលដែលតម្រូវឲ្យមានការពង្រឹងប្រសិទ្ធការងារដើម្បីឈានឆ្ពោះទៅកាន់ស្វ័យភាព និងភាពជាម្ចាស់នៃការងារក្នុងក្របខណ្ឌ MRC នៅថ្នាក់ជាតិ
- ការឆ្លើយតបទៅនឹងសំណើរបស់ គ.ជ.ទ.ម.ក ពីក្រសួង ស្ថាប័នជាសមាជិក និងសំណើពីលេខាធិការដ្ឋាន MRC ពេលខ្លះ មានការយឺតយ៉ាវ និងកៀកពេក ដែលធ្វើឲ្យ គ.ជ.ទ.ម.ក មិនអាចចាត់ចែងបន្តឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាពខ្ពស់
- ការអនុវត្តគម្រោង និងកម្មវិធីខ្លះនៅថ្នាក់ជាតិ មានការយឺតយ៉ាវ ដោយសារមិនទាន់ត្រូវបានអនុម័តលើឯកសារគម្រោង និងកម្មវិធីក្នុងកម្រិតតំបន់ ព្រោះពិបាកក្នុងការកំណត់ពេលវេលាប្រជុំ
- មិនទាន់មានភាពរលូនល្អក្នុងការអនុវត្តគម្រោង កម្មវិធីខ្លះ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ដោយមានការខ្វះខាតការទ្រទ្រង់ថវិកាពេញលេញពីដៃគូអភិវឌ្ឍលើគម្រោងដែលបានគ្រោង
- ការបន្តដំណើរការអនុវត្តវិមជ្ឈការមុខងារស្នូលរបស់គណៈកម្មការទន្លេមេគង្គដែលការអនុវត្តគម្រោងនានាត្រូវធ្លាក់ជាបន្ទុកទទួលខុសត្រូវបណ្តើរៗរបស់ក្រសួង-ស្ថាប័នជាតិពាក់ព័ន្ធអនុលោម

តាមការប្តេជ្ញារបស់ប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកធ្វើជាម្ចាស់ការផ្នែកហិរញ្ញវត្ថុនៃស្ថាប័នគណៈកម្មការទន្លេមេគង្គក្នុងឆ្នាំ ២០៣០ និងការកែសម្រួលឡើងវិញនូវរូបមន្តនៃការបង់វិភាគទានទៅគណៈកម្មការទន្លេមេគង្គ ដែលតម្រូវឲ្យមានការកើនឡើងនូវអត្រានៃការបង់វិភាគទាននេះនាពេលខាងមុខ ។

**៤-វិធានការគោលនយោបាយ សម្រាប់រួមចំណែកអនុវត្ត អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិធានការ គោលនយោបាយ ដែលមានចរិតតាមវិស័យ និងអន្តរវិស័យសម្រាប់ឆ្នាំ ២០២១-២០២៣ ៖**

**ក-ក្រសួងធនធានទឹក និងឧតុនិយម ៖**

ធនធានទឹកបានចូលរួមគាំទ្រដល់តម្រូវការក្នុងវិស័យជាច្រើននៃសេដ្ឋកិច្ចជាតិ ។ ការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងវិស័យធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយមត្រូវផ្តោតយកចិត្តទុកដាក់លើវិធានការសំខាន់ ៖

- ការប្រើប្រាស់ជាអតិបរមានូវសក្តានុពលនៃប្រព័ន្ធធារាសាស្ត្រ ដើម្បីជាផលប្រយោជន៍សម្រាប់ការដោះស្រាយបញ្ហាទឹកដល់វិស័យកសិកម្ម
- ការធានាឲ្យមានការចូលរួមជាច្រើនជាងមុនពីកសិករទាំងឡាយ នៅក្នុងសហគមន៍កសិករប្រើប្រាស់ទឹក
- ការពង្រឹងនូវដំណើរការនៃការផ្តល់អាទិភាពដល់ការស្តារឡើងវិញ ការកសាង ការថែទាំ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ដូចជា អាងស្តុកទឹក ប្រឡាយទឹក ប្រព័ន្ធដោះទឹក ប្រព័ន្ធត្រួតពិនិត្យទឹកជំនន់ ទំនប់ការពារទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើនលទ្ធភាពស្រោចស្រពដល់ផ្ទៃដីដាំដុះ និងការពារផលិកម្មកសិកម្ម
- ការយកចិត្តទុកដាក់លើមតិយោបល់ និងសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត និងការធានាបាននូវសុវត្ថិភាពស្បៀង ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដើម្បីធ្វើឲ្យសម្រេចបាននូវប្រព័ន្ធអេកូឡូស៊ី និងទឹកដែលគ្មានការបំពុលនៅក្នុងអាងទន្លេមេគង្គ និងបន្តសិក្សាពីការប្រើប្រាស់ធនធានទឹក ក្នុងទន្លេ បឹងបួរ ស្ទឹង និងបឹងទន្លេសាប
- ការធានាឲ្យមានការចូលរួមរបស់ស្ថាប័ននានា និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ
- ការធានាឲ្យមានទឹកស្អាតគ្រប់គ្រាន់ ហើយគុណភាពទឹកឆ្លើយតបទៅនឹងតម្រូវការនៅគ្រប់វិស័យពេញមួយឆ្នាំ និងដើម្បីការពារប្រព័ន្ធអេកូឡូស៊ី
- ការកាត់បន្ថយនៅកម្រិតតិចបំផុតនូវផលប៉ះពាល់ពីទឹកជំនន់ និងកសាងសមត្ថភាព ដើម្បីការពារទប់នឹងទឹកជំនន់ ដែលបណ្តាលមកពីទឹកភ្លៀង និងទឹកសមុទ្រ
- ការបញ្ចៀសការបំពុលធនធានទឹក ដើម្បីការពារប្រព័ន្ធអេកូឡូស៊ី ជាពិសេសធនធានមច្ឆាជាតិ ។

**ខ-អាជ្ញាធរទន្លេសាប ៖**

ដើម្បីរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងផែនការអភិវឌ្ឍជាតិ ២០១៩-២០២៣ អាជ្ញាធរទន្លេសាប ចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ដូចខាងក្រោម ៖

- ចូលរួមគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប និងតំបន់ពាក់ពន្ធ័ឲ្យមាននិរន្តរភាព

- ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា
- សិក្សាស្រាវជ្រាវ និងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តរាល់បទបញ្ជាផ្ទាល់ពីប្រមុខរាជរដ្ឋាភិបាល ក្នុងការការពារធនធានធម្មជាតិ និងជីវចម្រុះនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ។

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយ តាមវិស័យពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលឲ្យមានកំណើនការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឲ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋអាង្គធរទន្លេសាប ដែលជាអង្គភាព ដើរតួនាទីក្នុងការសម្របសម្រួលដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធ មានគោលបំណងគោលនយោបាយយ៉ាងច្បាស់លាស់គឺ ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយនិរន្តរភាព សម្រាប់ចូលរួមលើកកម្ពស់គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាតិដែលបានកំណត់ក្នុងផែនការយុទ្ធសាស្រ្តជាតិ (២០១៩-២០២៣) និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដែលជា " របៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ច " ក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហវត្សនៃកម្ពុជា ។

**គ-គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ៖**

- ជម្រុញលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ នីតិវិធីគ្រប់គ្រងការប្រើប្រាស់ទឹក គោលការណ៍ណែនាំ និងបទប្បញ្ញត្តិនានាជាធរមាន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃការទន្លេមេគង្គ និងប្រសិទ្ធភាពការងារស្ថាប័ន
- ពិនិត្យលើវឌ្ឍនភាព នៃការអនុវត្តសេចក្តីថ្លែងការណ៍ នៃកិច្ចប្រជុំកំពូល គ.ទ.ម ទាំង ៣ លើក គឺលើកទី១ នៅឆ្នាំ ២០១០ លើកទី២ នៅឆ្នាំ ២០១៤ និងលើកទី៣ នៅឆ្នាំ ២០១៨ ដែលប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិក បានប្តេជ្ញាចិត្តអំពីស្វ័យភាពផ្នែកហិរញ្ញវត្ថុដោយប្រទេសជាសមាជិកត្រឹមឆ្នាំ ២០៣០
- ពិនិត្យ និងអនុម័តលើឯកសារយុទ្ធសាស្រ្តអភិវឌ្ឍន៍អាង ឆ្នាំ២០២១-២០៣០ និងផែនការយុទ្ធសាស្រ្តសម្រាប់ឆ្នាំ ២០២១-២០២៥ និងយុទ្ធសាស្រ្តតាមវិស័យ មានដូចជាផ្នែក វារីអគ្គិសនី បរិស្ថានទឹកជំនន់ ជាដើម
- ពិនិត្យ ពិចារណា និងផ្តល់អនុសាសន៍លើលទ្ធផលនៃការសិក្សាស្តីពី ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ ដោយរាប់បញ្ចូលទាំងផលប៉ះពាល់បង្កឡើងដោយគម្រោងវារីអគ្គិសនី នៅលើទន្លេមេនៃទន្លេមេគង្គ ដើម្បីឲ្យ គ.ទ.ម និងប្រទេសជាសមាជិក យកទៅអនុវត្តនិងបញ្ចូលក្នុងយុទ្ធសាស្រ្តអភិវឌ្ឍន៍អាង
- បន្តពិនិត្យតាមដាន និងស្វះស្វែងរកធនធានសម្រាប់ការអនុវត្តផែនការចង្អុលទិសថ្នាក់ជាតិ ២០១៦-២០២០ និងរៀបចំផែនការចង្អុលទិសថ្នាក់ជាតិសម្រាប់រយៈពេល ០៥ ឆ្នាំបន្ទាប់
- បន្តសហការចូលរួមជាមួយ គ.ទ.ម និងប្រទេសជាសមាជិក ដើម្បីបន្តលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ ១៩៩៥ សេចក្តីថ្លែងការណ៍ក្រុងសៀមរាបឆ្នាំ ២០១៨ នៃកិច្ចប្រជុំកំពូល គ.ទ.ម លើកទី៣ សំដៅដើម្បីទាញយកផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការ សម្រាប់ប្រទេស និងប្រជាជាតិឲ្យបានកាន់តែល្អប្រសើរ

